ទំព័រទី១៖ **ទស្សនាវដ្ដី "និប៉ុនិកា" លេខ៣៦** ស្វែងយល់ពីប្រទេសជប៉ុន

# ចិក និងក្រដាសទាំងអស់នៅប្រទេសជប៉ុន

ទំព័រទី២៖

ទស្សនាវដ្ដីលេខ៣៦នេះ និយាយអំពី «**ចិក និងក្រដាសទាំងអស់នៅប្រទេសជប៉ុន**»

ទោះបីជាសព្វថ្ងៃនេះ ការប្រាស្រ័យទាក់ទងគ្នាបែបឌីជីថលដែលមិនចាំបាច់ត្រូវការប្រើក្រដាសកំពុងរីកចម្រើនក៏ដោយ ក៏ចំណង់ចំណូលចិត្តក្នុងការសរសេរ និងគូរដោយដៃនៅតែមានប្រជាប្រិយភាពនៅក្នុងប្រទេសជប៉ុន។ ពិភពសម្ភារៈការិយាល័យរបស់ជប៉ុនបានឆ្លុះបញ្ចាំងពីការពិតទាំងនេះ។

ទំព័រទី៣៖

មាតិកា

- សម្ភារៈការិយាល័យដ៏លេចធ្លោរបស់ប្រទេសជប៉ុន
- ការវិវត្តឥតឈប់ឈរនៃសម្ភារៈការិយាល័យជប៉ុន
- កន្លែងដែលនាំឱ្យអ្នកកាន់តែចង់សរសេរ
- ការលេងពណ៌ដ៏រីករាយ
- ឧបករណ៍ដែលវិចិត្រករម៉ានហ្គាពេញចិត្ត
- ដំណើរកំសាន្តនិម្មិតទូទាំងប្រទេសជប៉ុន៖ សម្ភារៈការិយាល័យក្នុងតំបន់
- រសជាតិជប៉ុន៖ ពេលដែលត្រូវទទួលទាន! ស្ករគ្រាប់ គុមិអាម៉ិ
- ដើរកំសាន្តប្រទេសជប៉ុន៖ អ៊ិឈិហ្សេន
- វត្ថុអនុស្សាវរីយ៍របស់ជប៉ុន៖ ក្រដាសកត់ចំណាំប្លែកៗ

*រូបភាពខាងលើ៖ សូមមើលលម្អិតនៅទំព័រទី៤–៧អំពីសម្ភារៈសម្រាប់ការសរសេរទាំងនេះ។*

*រូបភាពលើគម្រប៖ ខ្មៅដៃពណ៌ចំនួន៥០០ (រូបភាព៖ Felissimo)*

និប៉ុនិកា ត្រូវបានបោះពុម្ពជាភាសាជប៉ុន និងប្រាំមួយភាសាផ្សេងទៀត រួមមានភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដើម្បីណែនាំទៅកាន់ពិភពលោកអំពីប្រជាជន និងវប្បធម៌ជប៉ុនសព្វថ្ងៃនេះ។

ចំណងជើងទស្សនាវដ្ដី និប៉ុនិកា មានប្រភពមកពីពាក្យ "និប៉ុន" ពាក្យជប៉ុន ដែលមានន័យថា ប្រទេសជប៉ុន។

*ទស្សនាវដ្តីលេខ៣៦* R-060426

*បោះពុម្ពដោយក្រសួងការបរទេសនៃប្រទេសជប៉ុន*

*២-២-១ កាស៊ីមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*

*គេហទំព័រផ្លូវការរបស់ក្រសួង [https://www.mofa.go.jp/](https://www.mofa.go.jp/)*

ទំព័រទី៤៖

## សម្ភារៈការិយាល័យដ៏លេចធ្លោរបស់ប្រទេសជប៉ុន

ក្រុមចម្រុះនៃប៊ិក សៀវភៅកត់ត្រា ខ្មៅដៃ និងប៊ិកប៉ាកកាជាដើម។

សម្ភារៈទាំងនេះគ្រាន់តែជាសមិទ្ធិផលមួយចំនួនរបស់អ្នកផលិតសម្ភារៈការិយាល័យ និងសិប្បករក្នុងដំណើរស្វែងរកសិល្បៈនៃការសរសេរ និងគំនូរឱ្យល្អឥតខ្ចោះ។ ចំណង់ចំណូលចិត្តរបស់ពួកគេ គឺជាបុព្វហេតុធ្វើឱ្យសម្ភារៈការិយាល័យរបស់ជប៉ុនក្លាយជាស្តង់ដារពិភពលោក។

**●បរីពេន (ប៊ិក)**

**ស៊ុយសេ-បរីពេន (ប៊ិកទឹក)៖** នៅឆ្នាំ១៩៦៤ ក្រុមហ៊ុន OHTO Co., Ltd. បានចេញលក់នូវ "W" ជាប៊ិកទឹកដំបូងគេរបស់ពិភពលោក ដែលទទួលបានកេរ្តិ៍ឈ្មោះទាំងនៅក្នុងប្រទេសជប៉ុន និងជុំវិញពិភពលោកសម្រាប់ការសរសេរយ៉ាងរលូន ដែលប៊ិកនេះធ្វើចេញពីប្រេង។ ស៊ុយសេ-បរីពេន ផលិតផលចុងក្រោយ CR01 មានការរចនាប្លែកពីគេដែលការពារចុងមិនឱ្យស្ងួតសូម្បីតែបើកគម្របទុកចោល។ (រូបភាព៖ ក្រុមហ៊ុន OHTO Co., Ltd.)

*"W" ប៊ិកទឹកពណ៌ខ្មៅដំបូងគេរបស់ពិភពលោក*

**បរីសាអ៊ីន(ប៊ិកពណ៌)៖** បរីសាអ៊ីន ជាប៊ិកដំបូងរបស់ពិភពលោកដែលប្រើទឹកថ្នាំជាទឹកដែលមានសារជាតុពណ៌។ បន្ថែមនូវសារជាតុរលោង ដើម្បីសរសេរបានស្រួល និងធ្វើឱ្យទឹកថ្នាំជាប់បានយូរដោយប្រើទឹកថ្នាំធ្វើចេញពីប្រេង។ ទឹកថ្នាំដែលស្រដៀងនឹងចាហួយអាចផ្ទុកសារជាតុពណ៌ជាច្រើនប្រភេទ ដែលបណ្តាលឱ្យបង្កើតបានប៊ិកដែលមានពណ៌ជាច្រើន។ (រូបភាព៖ SAKURA COLOR PRODUCTS CORPORATION)

**ហ្វ្រីគីស្សុន-បរីពេនណុកគី(ប៊ិកលុបបាន)៖** ប៊ិកដែលមានជ័រមូលនៅខាងចុង គឺជាប៊ិកដែលអាចលុបបាន គឺជាការធ្វើបដិវត្តពិភពសម្ភារៈការិយាល័យ។ ជ័រលុបពិសេសនៅខាងចុងប៊ិក នៅពេលជួបជាមួយកម្លាំងកកិតបង្កើតបានជាកំដៅធ្វើឱ្យទឹកថ្នាំប៊ិកមានប្រតិកម្មប្រែក្លាយជាពណ៌ថ្លា ដែលវាជាយុគសម័យថ្មីមួយនៃប៊ិក។ (រូបភាព៖ PILOT Corporation)

**ជេតតុស្ទ្រីមី ស្តានដាដុ(ប៊ិកជេតស្ទ្រីម)៖** ប៊ិកនេះមានទឹកថ្នាំដែលមានជាតិស្អិតទាបបំផុតដែលកាត់បន្ថយការកកិត ដើម្បីផ្តល់នូវការសរសេរយ៉ាងរលូន និងជិតច្បាស់។ ចាប់តាំងពីបើកលក់ក្នុងឆ្នាំ២០០៦មក ប៊ិកនេះបានជំរុញឱ្យមានការរីកចម្រើនជាសកលនូវប៊ិកដែលមានជាតិប្រេង និងជាតិស្អិតទាប។ (រូបភាព៖ MITSUBISHI PENCIL COMPANY, LIMITED)

ទំព័រទី៥៖

●**ស្យ៉ាពីពេនស៊ីរី (ខ្មៅដៃចុច)**

**គឺរុតុហ្គា៖** ខ្មៅដៃចុចនេះរក្សាបាននូវមុខមុតស្រួចរបស់វា ពីព្រោះក្បាលបង្វិលជានិច្ច ដែលធានាថាស្មើគ្នាល្អ នៅពេលអ្នកសរសេរ។ ខ្មៅដៃចុចម៉ាក គឺរុតុហ្គា មានការលក់សរុបលើសពី១០០លានដើម ចាប់តាំងពីបើកលក់ក្នុងឆ្នាំ២០០៨។ (រូបភាព៖ MITSUBISHI PENCIL COMPANY, LIMITED)

**ហាយប៉ូលីម៉ា-ស៊ីន (បណ្តូលខ្មៅដៃចុចមានសារជាតុប៉ូលីម៉ែរខ្ពស់)៖** បណ្តូលខ្មៅដៃធន់ល្អ ត្រូវបានបង្កើតឡើងដោយទាញយកអត្ថប្រយោជន៍ពីលក្ខណៈសម្បត្តិនៃជ័រសំយោគដែលបង្កើតកាបូនអ៊ីដ្រាតនៅពេលមានកំដៅ និងរឹង ផ្ទុំជាមួយធ្យូងថ្មម៉្យាង សម្រាប់ធ្វើបណ្តូលខ្មៅដៃ ដែលអាចទប់ទល់នឹងសម្ពាធប៊ិក។ នៅឆ្នាំ១៩៦០ បណ្តូលខ្មៅដៃទំហំ០.៩មីលីម៉ែត្រត្រូវបានចេញលក់ បន្ទាប់មក០.៧មីលីម៉ែត្រ និងនៅឆ្នាំ១៩៦២ ទំហំ០.៥ មីលីម៉ែត្រ។ (រូបភាព៖ Pentel Co., Ltd.)

●**សាអ៊ីនពេន និង ហ្វូជិពេន(ប៊ិកជក់ពណ៌ និងប៊ិកជក់)**

**អាតុប៊ឺរាសស៊ុ (ប៊ិកជក់សិល្បៈ)៖** នៅប្រទេសជប៉ុន នៅលើអំណោយ និងការសរសេរអក្សរជារឿយៗត្រូវបានសរសេរដោយជក់ និងទឹកខ្មៅ ហើយទម្លាប់នេះត្រូវបានបដិវត្តក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ដោយការប្រើប្រាស់ប៊ិកជក់វិញ ដែលធ្វើឱ្យការសរសេរអក្សរផ្ចង់បានយ៉ាងងាយស្រួល។ បច្ចុប្បន្ននេះ ប៊ិកជក់កាន់តែមានពណ៌ច្រើនឡើងឥតឈប់ឈរ និងជាឧបករណ៍សិល្បៈដ៏ពេញនិយមនៅក្រៅប្រទេសជប៉ុន។ ឥឡូវនេះមាន២៤ពណ៌ផ្សេងគ្នាដែលអាចលាយបញ្ចូលគ្នាដើម្បីបង្ហាញចេញនូវសិល្បៈ។ (រូបភាព៖ Pentel Co., Ltd.)

**សាអ៊ីនពេន(ប៊ិកជក់ពណ៌)៖** ប៊ិកទឹកថ្នាំពណ៌ដែលមានជាតិសរសៃដំបូងគេរបស់ពិភពលោកត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៦៣។ ធ្វើពីសរសៃអាគ្រីលីក ចុងប៊ិកផ្តល់នូវការសរសេរដែលរួមបញ្ចូលគ្នានូវគុណភាពទាំងទឹកប៊ិក និងជក់។ ប៊ិកនេះបានក្លាយជាប្រធានបទដ៏ក្តៅគគុកមួយនៅសហរដ្ឋអាមេរិក នៅពេលដែលវាត្រូវបានប្រគល់ជូនលោកប្រធានាធិបតី ចនសុន (Johnson) ហើយក្រោយមកត្រូវបានគេនាំយកទៅជិះនៅលើយានអវកាសណាសា។ ប៊ិកជក់ពណ៌នេះ ជាប៊ិកលក់ដាច់បំផុតដែលពេញនិយមជុំវិញពិភពលោក។ (រូបភាព៖ Pentel Co., Ltd.)

**ម៉ាគុតាស៊ុ(ប៊ិកហាយឡាយពីរពណ៌)៖** ប៊ិកមួយដើមដែលមានគន្លឹះបង្វិលដើម្បីប្តូរពណ៌ពីរផ្សេងគ្នា។ មុខងារដ៏ងាយស្រួលនេះមានប្រយោជន៍ជាពិសេសសម្រាប់ការបែងចែកពណ៌ ដែលអ្នកចង់រំលេច ឬសម្គាល់កិច្ចការ ដើម្បីជួយគ្រប់គ្រងកាលវិភាគរបស់អ្នក។ (រូបភាព៖ KOKUYO Co., Ltd.)

**គីរីកគីប៊ីរ៉ាយតុ(ប៊ិកហ្វឺតចុច)៖** ទឹកថ្នាំនៅក្នុងប៊ិកហ្វឺតចុចទាំងនេះ ត្រូវបានបង្កើតឡើងដើម្បីងាយស្រួលស្រូបយកសំណើមពីខ្យល់ និងរក្សាទឹកថ្នាំមិនឱ្យស្ងួត ទោះបីជាប៊ិកត្រូវបានទុកចោលក៏ដោយ។ (រូបភាព៖ ZEBRA CO., LTD.)

<u>ទំព័រទី៦</u>៖

*សិប្បកម្ម ប៊ិកប៉ាកកា ផលិតដោយប្រើបច្ចេកទេសគំនូរម៉ាគិ-អិ របស់ជប៉ុនបានបន្តពីមួយជំនាន់ទៅមួយជំនាន់អស់រយៈពេល១០០ឆ្នាំហើយ។ (រូបភាព៖ PILOT Corporation)*

**●ម៉ាននេនហ៊ីតស៊ឺ(ប៊ិកប៉ាកកា)**

**ណាហ្គិណាតា តុហ្គិ ម៉ាននេនហ៊ីតស៊ឺ(ប៊ិកប៉ាកកា មុខស្រួចវែង)៖** ក្រុមហ៊ុនផលិតសម្ភារៈការិយាល័យជប៉ុនជាច្រើនមានជំនាញក្នុងការរចនាប៊ិកប្រភពដើមរបស់ពួកគេ។ ណាហ្គិណាតា តុហ្គិ ផលិតដោយ The Sailor Pen Co., Ltd. គឺជាឧទាហរណ៍មួយ។ ចំណុចធំជាងធម្មតាត្រូវភ្ជាប់នៅចុងប៊ិកដូចជារាងដាវវែងដ៏រលោង និងមុត ("ណាហ្គិណាតា" ជាភាសាជប៉ុនមានន័យថាផ្លែកំបិតវែង) ។ ការរចនាចុងប៊ិកបែបនេះធ្វើឱ្យតួអក្សរជិតល្អ នៅពេលដែលកាន់ប៊ិកសរសេរផ្តេក ហើយគំនូសអក្សរស្តើងនៅពេលអ្នកកាន់ប៊ិកសរសេរត្រង់ ដែលប៊ិកនេះនឹងធ្វើឱ្យអ្នកបានតួអក្សរកាន់ជិដ៏ស្រស់ស្អាត។ (រូបភាព៖ THE SAILOR PEN CO., LTD.)

*គំនូសអក្សរស្តើង នៅពេលដែលសរសេរបញ្ឈរ។*

*គំនូសអក្សរឌិតល្អ នៅពេលដែលសរសេរផ្តេក។*

**ខាស៊ឺតាមី អ៊ុរុស៊ិ (ម្រ័ក្សណ៍ខ្មុកប្រពៃណី)៖** ប្រហែលជា១០០ឆ្នាំមុន ប៊ិកប៉ាកកាដែលធ្វើពីម្រ័ក្សណ៍ខ្មុកដែលមានពណ៌ត្រូវបានបង្កើតឡើង។ នៅឆ្នាំ១៩២៥ ក្រុមហ៊ុនPILOT បានបញ្ចេញប៊ិកប៉ាកកាគំនូរម៉ាគិ-អិ(រូបខាងឆ្វេង) ដែលមានការរចនាម៉ូដលាបពណ៌មាស និងម្សៅផ្សេងៗទៀត។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ មិនត្រឹមតែប៊ិកប៉ាកកាគំនូរម៉ាគិ-អិប៉ុណ្ណោះទេ ប៊ិកប៉ាកកាម៉ូដថ្មីៗដែលមានតម្លៃថ្លៃផ្សេងទៀតដែលលាបអ៊ុរុស៊ិ(ម្រ័ក្សណ៍ខ្មុក)ពណ៌ក្រហម និងខ្មៅ រលើបរលោងដូចស្រោបកញ្ចក់ បានទទួលការពេញនិយម។ (រូបភាព៖ PILOT Corporation)

*ប៊ិកប៉ាកកាគំនូរម៉ាគិ-អិតាំងពីឆ្នាំ១៩២៥*

ទំព័រទី៧៖

●អេនពិត្ស៊ឺ(ខ្មៅដៃឈើ)

**ហុគុសាអ៊ីន៖** បណ្តូលខ្មៅដៃដែលផលិតជាពិសេសនៅក្នុងខ្មៅដៃឈើទាំងនេះ គឺប្រហែលមាំជាងពីរដងនៃបណ្តូលខ្មៅដៃធម្មតាដែលអាចគូសសង្កត់បានខ្លាំងដូចជា 3B និង4B។ ខ្មៅដៃឈើទាំងនេះប្រើល្អសម្រាប់ការគូរ និងផាត់ពណ៌ ព្រោះធ្យូងថ្មម៉្យាងដែលប្រើសម្រាប់ធ្វើបណ្តូលខ្មៅដៃនោះ វាមិនធ្វើឱ្យប្រតាក ឬប្រឡាក់ដៃទេ។ ខ្មៅដៃឈើដែលមានពណ៌ត្រូវបានគេហៅថា ហុគុសៃ ប្លូ (Hokusai Blue) ត្រូវបានបំផុសគំនិតដោយវិចិត្រករគំនូរបោះពុម្ព អ៊ុគិយ៉ូអិ កាត្ស៊ឹស៊ិកា ហុគុសៃ (ukiyoe Katsushika Hokusai)។ (រូបភាព៖ KUTSUWA CO., LTD.)

**ហៃយូនី អាតុសេតតុ(ឈុតសិល្បៈហៃយូនី)៖** ឈុតនេះមានខ្មៅដៃឈើដែលមានកម្រិតភាពរឹងនៃបណ្តូល២២ផ្សេងៗគ្នា ចាប់ពីកម្រិត 10H ដល់ 10B។ បណ្តូលទាំងនេះត្រូវបានផលិតចេញពីល្បាយទម្រង់នៃធ្យូងថ្មម៉្យាងសម្រាប់ធ្វើបណ្តូលខ្មៅដៃ និងដីឥដ្ឋដែលមានភាពសុទ្ធខ្លាំង ដើម្បីផ្តល់នូវពណ៌ខ្មៅរលោង។ ខ្មៅដៃឈើទាំងនេះគឺជាសម្ភារៈសិល្បៈសម្រាប់គំនូរដែលត្រូវបានគេនិយមចូលចិត្តប្រើប្រាស់ជាយូរមកហើយ។ (រូបភាព៖ MITSUBISHI PENCIL COMPANY, LIMITED)

●ណោតុ(សៀវភៅសរសេរ)

**ចាប៉ុនិកា ហ្គាគុស្ស៊ូចូ(សៀវភៅសរសេរចាប៉ុនិកាហ្គាគុស្ស៊ូចូ)៖** ចាប់តាំងពីការចេញលក់នៅឆ្នាំ១៩៧០ សៀវភៅសរសេរម៉ាកចាប៉ុនិកាហ្គាគុស្ស៊ូចូ បានក្លាយជាចំណូលចិត្តរបស់កុមារជប៉ុន។ ប្រហែលជា៥០ប្រភេទនៃក្រឡាចក្រត្រង្គ និងបន្ទាត់ដែលមានក្នុងសៀវភៅនេះផ្តល់ជូននូវប្រភេទ និងទំហំខុសៗគ្នាអាស្រ័យកម្រិតថ្នាក់ និងមុខវិជ្ជាផ្សេងៗរបស់សាលា ក៏ដូចជាសម្រាប់ការប្រើប្រាស់ផ្សេងៗគ្នា ដូចជាការសរសេរអត្ថបទ ឬការអនុវត្តសរសេរតួអក្សរកានជិជាដើម។ (រូបភាព៖ SHOWA NOTE CO., LTD.)

**ខ្យាំប៉ប៉ាស៊ុ-ណោតុ(សៀវភៅសរសេរខេមភើស)៖** សៀវភៅសរសេរបុរាណនេះ មិនត្រឹមតែសិស្សានុសិស្សប៉ុណ្ណោះទេ ប៉ុន្តែគ្រប់ជំនាន់ទាំងអស់សុទ្ធតែជាអ្នកគាំទ្រសៀវភៅនេះ។ សៀវភៅខេមភើសនេះមានក្រឡាបន្ទាត់បែងចែកទៅតាមគោលបំណងរបស់អ្នកប្រើប្រាស់ដូចជា បន្ទាត់ក្រឡាចត្រង្គ បន្ទាត់បញ្ឈរ និងបន្ទាត់ចំនុចតូចៗ ក៏ដូចជាបន្ទាត់កាត់ទទឹងមានចន្លោះពី ៥ទៅ ១០មីលីម៉ែត្រផងដែរ។ សៀវភៅកត់ត្រាទាំងនេះក៏ត្រូវបានផលិតឡើងដោយគិតគូរពីបរិស្ថាន ដោយប្រើក្រដាសពីឈើដែលមានលិខិតបញ្ជាក់ពីការប្រើប្រាស់ព្រៃឈើនៅទំព័រខាងក្នុង។ (រូបភាព៖ KOKUYO Co., Ltd.)

ទំព័រទី៨៖

## ការវិវត្តឥតឈប់ឈរនៃសម្ភារៈការិយាល័យជប៉ុន

ការផ្គត់ផ្គង់ផលិតផលគ្មានទីបញ្ចប់ជាមួយនឹងមុខងារដ៏ប្រណិត និងទំនិញច្រើនប្រភេទរាប់មិនអស់។ ហេតុអ្វីបានជាពិភព សម្ភារៈការិយាល័យជប៉ុនសម្បូរបែប?តាមដានការវិវត្តនៃសម្ភារៈការិយាល័យនៅប្រទេសជប៉ុនជាមួយនឹងការពន្យល់ពីអ្នកជំនាញ។

*សម្ភាសន៍ជាមួយ លោក តាកាបាតាកិ ម៉ាសាយូគិ*

***ការូតា៖*** *កាតល្បែងប្រពៃណីជប៉ុន ត្រូវបានលេងដោយប្រកួតចាប់រូបភាពកាត តាមការអានកាត ហៅថា"អ៊ុតាការូតា(ចម្រៀងការូតា)" ColBase*

***អ៊ុគិយ៉ុ-អិ៖*** *គំនូរបោះពុម្ពដោយផ្ទាំងឈើចម្រុះពណ៌ត្រូវបានបង្កើតឡើងក្នុងកំឡុងសម័យអេដុ។ គំនូរជាច្រើនត្រូវបានសរសេរអក្សរនៅក្នុងនោះផងដែរ។ គំនូរ Gotenyama Hanami Mitatehana no Utage ដោយ អ៊ុតាហ្គាវ៉ា ហ៊ីរ៉ូស៊ិហ្គិ។ ប្រមូលចងក្រងដោយ៖ បណ្ណាល័យសភាជាតិ*

ប្រទេសជប៉ុនត្រូវបានគេស្គាល់ថាជាកន្លែងផលិតសម្ភារៈការិយាល័យ ហើយជាការពិតដែលភាគច្រើននៃសម្ភារៈការិយាល័យថ្មីៗភាគច្រើនត្រូវបានបង្កើតឡើងតាំងពីទសវត្សរ៍ឆ្នាំ២០០០ មកពីប្រទេសជប៉ុន។ ទីមួយគឺ ប៊ិកដែលមានជ័រមូលអាចលុបបាន "ហ្វ៊ុរីគឹស្សុន-បរឹពេនណុកគឹ(ប៊ិកលុបបាន)[*១]" និងប៊ិកដែលមានជាតិស្អិតទាបបំផុត "ជេតតុស្តុរីមឹ ស្តានដាដុ(ប៊ិកជេតស្ទ្រីម)[*២]"។

សម្ភារៈការិយាល័យរបស់ជប៉ុនត្រូវបានគេវាយតម្លៃខ្ពស់ចំពោះគុណភាព មុខងារ ការរចនា និងការលេងកំសាន្ត។ អ្វីដែលគួរឱ្យកត់សម្គាល់ជាពិសេសនោះ គឺឧបករណ៍សរសេរដែលរួមបញ្ចូលបច្ចេកវិទ្យាទំនើបចុងក្រោយបំផុតអាចត្រូវបានទិញក្នុងតម្លៃថោកត្រឹមតែប៉ុន្មានរយយ៉េនប៉ុណ្ណោះ។ បើប្រៀបធៀបទៅនឹងប្រទេសផ្សេងទៀត ប្រទេសជប៉ុនហាក់ដូចជាប្លែកពីគេក្នុងអាកប្បកិរិយារបស់ខ្លួនក្នុងការបន្តកែលម្អឥតឈប់ឈរ សូម្បីតែទំនិញទាំងនោះហាក់ដូចជាឈានដល់កម្រិតកំពូលក៏ដោយ ប៉ុន្តែនៅតែបន្តផ្តោតលើការអោក់រអួលតិចតួចបំផុតចំពោះអ្នកប្រើប្រាស់។

### ប្រទេសនៃសម្ភារៈការិយាល័យ ប្រទេសនៃក្រដាស

នៅពេលគិតអំពីទំនាក់ទំនងរវាងប្រជាជនជប៉ុន និងសម្ភារៈការិយាល័យ វាជារឿងសំខាន់ដែលត្រូវកត់សម្គាល់ថា ប្រទេសជប៉ុនគឺជាប្រទេសដែលមានក្រដាសតាំងពីបុរាណកាលមក។ វិធីសាស្ត្រនៃការផលិតក្រដាសនាពេលបច្ចុប្បន្នពីសរសៃរុក្ខជាតិ ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសចិនប្រហែលសតវត្សទី២ មុនគ្រឹស្តសករាជ ហើយវិធីសាស្ត្រផលិតនេះបានរីករាលដាលដល់ប្រទេសជប៉ុនក្នុងសតវត្សទី៧។ ក្នុងសតវត្សទី១៣ ក្រដាសត្រូវបានណែនាំទៅកាន់ទ្វីបអឺរ៉ុបតាមរយៈផ្លូវសូត្រ ដូច្នេះអាចនិយាយបានថាប្រទេសជប៉ុនគឺជាប្រទេសផលិតក្រដាសកម្រិតខ្ពស់ឈានមុខគេ។ ប្រហែល ៧០% នៃប្រទេសជប៉ុនមានព្រៃឈើ និងមានទន្លេជាច្រើន ដូច្នេះហើយមានរុក្ខជាតិ និងទឹកគ្រប់គ្រាន់ដែលអាចប្រើប្រាស់ជាវត្ថុធាតុដើម។ ដូច្នេះ ក្រដាសមិនត្រឹមតែប្រើសម្រាប់

សរសេរប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់សិប្បកម្ម គ្រឿងសង្ហារិម និងសម្លៀកបំពាក់ផងដែរ។ ក្រដាសវ៉ាស៊ិ(Washi) ធ្វើដោយដៃត្រូវបានបង្កើតឡើងនៅទូទាំងប្រទេសជប៉ុន ហើយនៅដើមសតវត្សទី៨ គេបានពិភាក្សាគ្នាថា តើក្រដាសមកពីតំបន់ណាដែលសាកសមបំផុតក្នុងគោលបំណងសម្រាប់កម្មវិធីណាមួយ។ វាត្រូវបានគេនិយាយថា ក្រដាសវ៉ាស៊ិនាពេលនោះត្រូវបានរក្សាទុកនៅក្នុងឃ្លាំងស្យ៉ូសូអ៊ីន*៣ ហើយថាមហាក្សត្រីរបស់ព្រះចៅអធិរាជបានជ្រើសរើសពណ៌ក្រដាសវ៉ាស៊ិពីនៅក្នុងឃ្លាំងនោះដោយផ្ទាល់ព្រះអង្គ។ អស់រយៈពេល១,៣០០ឆ្នាំមកហើយ ប្រជាជនជប៉ុនបានជ្រើសរើសដោយប្រុងប្រយ័ត្ននូវសន្លឹកក្រដាសដែលពួកគេចូលចិត្ត។

<u>ទំព័រទី៩</u>៖

ម្យ៉ាងវិញទៀត នៅក្នុងប្រទេសមិនសូវមានធនធានក្រដាស សកម្មភាពនៃ "ការសរសេរនៅលើក្រដាស" ត្រូវបានចាត់ទុកថាជាឯកសិទ្ធិរបស់ពួកអភិជន និងអ្នកវណ្ណៈខ្ពស់តាំងពីយូរយារណាស់មកហើយ ដោយបង្ហាញថា ក្រដាសមានតម្លៃប៉ុណ្ណានាពេលនោះ។ ជាការពិតណាស់ នៅពេលដែលក្រដាសចាប់ផ្តើមប្រើដំបូងនៅក្នុងប្រទេសជប៉ុន វាត្រូវបានបម្រុងទុកសម្រាប់ថ្នាក់ដែលមានឯកសិទ្ធិ ដូចជាពួកអភិជនក្នុងតុលាការ និងពួកមន្ត្រីស្យូហ្គូន(ស្តេចត្រាញ់) ប៉ុន្តែវាកែប្រែយ៉ាងឆាប់រហ័សទៅកាន់ប្រជាជនទូទៅ។ ក្នុងកំឡុងសម័យអេដុ(១៦០៣-១៨៦៨) ល្បែងប្រជាប្រិយជប៉ុនការូតា គំនូរអ៊ុគីយ៉ុ-អ៊ិនៃជីវិតប្រចាំ និងកាវ៉ារ៉ាបាន(ខិត្តប័ណ្ណផ្សាយព័ត៌មាន) ព្រមទាំងឈិយ៉ុហ្គាមិ(ក្រដាសវ៉ាស៊ិមានក្រឡាចម្រុះពណ៌ប្រើសម្រាប់បត់អូរីហ្គាមិ ឬតុបតែងគ្រឿងសង្ហារិមជាដើម) បានក្លាយជាការពេញនិយមសម្រាប់ការកម្សាន្តដោយប្រជាជនសាមញ្ញ។ គំនិតដែលថាសម្ភារៈការិយាល័យ គឺជាឧបករណ៍សម្រាប់មនុស្សសាមញ្ញប្រហែលជាត្រូវបានបង្កើតឡើងនៅពេលនោះ។ នៅសតវត្សរ៍ទី១៩ សម្ភារៈការិយាល័យលោកខាងលិចដូចជា ប៊ិកប៉ាកកា ទឹកថ្នាំ និងក្រដាសដែលផលិតដោយម៉ាស៊ីនត្រូវបាននាំចូលមកក្នុងពិភពនៃទឹកខ្មៅ ជក់ និងក្រដាសវ៉ាស៊ិជប៉ុន ដែលពេលនោះហើយជនជាតិជប៉ុនបានយកតម្រាប់តាម និងកែលម្អលើបច្ចេកទេសទាំងនោះ។

បច្ចុប្បន្ននេះ នៅប្រទេសជប៉ុនមាន"កាមិហាគី" គឺជាការតាំងពិព័រណ៍ និងការលក់ក្រដាស ដែលកំពុងត្រូវបានប្រារព្ធឡើងនៅទីកន្លែងផ្សេងៗ ហើយ "បុនហ្គុចុស៊ិហាគី (ការតាំងពិព័រណ៍សម្ភារៈការិយាល័យស្ត្រី)" ដែលបានប្រារព្ធឡើងកាលពីខែធ្នូ ឆ្នាំ២០២៣ បានទាក់ទាញអ្នកចូលរួមចំនួន៤៥,០០០នាក់ ដែលជាការជោគជ័យដ៏ធំ។ ទំនាក់ទំនងដ៏រីករាយត្រូវបានបង្កើតឡើង ដែលក្រុមហ៊ុនផលិតសម្ភារៈការិយាល័យបញ្ចេញផលិតផលថ្មីៗជារៀងរាល់ឆ្នាំ ហើយអ្នកប្រើប្រាស់ក៏មានភាពពេញចិត្តចំពោះ ការវិវត្តនៃការសរសេរកាន់តែប្រណិត និងងាយស្រួលនៃការប្រើប្រាស់ផងដែរ។

## ការដាក់គំនិតទៅក្នុងពាក្យសរសេររបស់អ្នក

ហេតុអ្វីបានជាប្រជាជនជប៉ុនចូលចិត្តសម្ភារៈការិយាល័យខ្លាំងម្ល៉េះ ក្នុងសម័យកាលដែលមនុស្សគ្រប់គ្នាមានទូរសព្ទទំនើប និងការមិនសូវមានតម្រូវការក្រដាសកំពុងកើនឡើង? ហេតុផលមួយក្នុងចំណោមហេតុផលទាំងនេះ ប្រហែលជាជនជាតិជប៉ុនពូកែប្រមូលអារម្មណ៍ពីតួអក្សរ។ សំបុត្រដែលសរសេរដោយដៃបង្ហាញពីបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗ និងអាចបង្ហាញថា តើពួកគេបានសរសេរដោយប្រុងប្រយ័ត្ន ឬ ដោយប្រញាប់ប្រញាល់។ ជាពិសេស ជប៉ុនមានប្រព័ន្ធការសរសេរអក្សរដែលប្រើការបញ្ចូលគ្នានៃតួអក្សរបីប្រភេទគឺ កានជិ ហ៊ីរ៉ាហ្គាណា និងកាតាកាណា ហើយសូម្បីតែពាក្យដូចគ្នា តែសរសេរដោយតួអក្សរខុសគ្នា នោះ

ការបង្ហាញអារម្មណ៍ក៏មានភាពខុសប្លែកគ្នា អាស្រ័យលើប្រភេទតួអក្សរដែលពួកគេជ្រើសរើស។ នេះហើយជាមូលហេតុដែលពួកគេស្វែងរកការច្នៃប្រឌិតក្នុងការសរសេរ មិនមែនគ្រាន់តែការបញ្ជូនព័ត៌មានប៉ុណ្ណោះទេ។

ភាពជាប់ជំពាក់របស់ប្រជាជនជប៉ុនចំពោះសម្ភារៈការិយាល័យ និងស្មារតីមិននឿយណាយក្នុងការរិះរកអ្វីថ្មីៗរបស់វិស្វករនីមួយៗ ត្រូវបានឆ្លងកាត់ជាច្រើនជំនាន់មកហើយ។ ផ្អែកលើការលះបង់ទាំងកាយទាំងចិត្តបែបនេះ សម្ភារៈការិយាល័យរបស់ជប៉ុននៅតែបន្តវិវឌ្ឍទៅមុខ។

***កាវ៉ាបាន៖*** *ខិត្តប័ណ្ណដែលបោះពុម្ពលើឈើ បានរាយការណ៍ព័ត៌មាននៅតាមដងផ្លូវ។ រូបភាពនៅលើខិត្តប័ណ្ណនេះ បង្ហាញពីការខូចខាតដែលបណ្ដាលមកពីការរញ្ជួយដីនៅអេដុ សតវត្សទី១៩។ (រូបភាព៖ Aflo)*

***ឈិយ៉ុហ្គាមិ៖*** *សន្លឹកក្រដាសវ៉ាស៊ិ បោះពុម្ពដោយមានក្រឡាចម្រុះពណ៌។ ប្រើសម្រាប់ផលិតផលសិប្បកម្ម និងរបស់របរផ្សេងៗទៀត។ (រូបភាព៖គុរីហារ៉ា អុសាមុ)*

***បុនហ្គុចុស៊ិហាគឺ៖*** *សម្ភារៈការិយាល័យផ្សេងៗ គិតចាប់ពីប្រដាប់ប្រដាសរសេរ រហូតដល់ស្ទីគ័រ ត្រូវបានដាក់តាំងបង្ហាញ។ (រូបភាព៖ គណៈកម្មាធិការរៀបចំពិព័រណ៍បុនហ្គុចុស៊ិហាគឺ)*

**១. សូមមើលទៅទំព័រទី៤*

**២. សូមមើលទៅទំព័រទី៤*

**៣. ឃ្លាំងស្តុកទ្រព្យសម្បត្តិអធិរាជនៅប្រាសាទតូដៃជិ ក្នុងទីក្រុងណារ៉ា។*

***លោក តាកាបាតាកិ ម៉ាសាយ៉ុគិ***

*លោកតាកាបាតាកិ កើតនៅខេត្តកាហ្គាវ៉ា ក្នុងឆ្នាំ១៩៧៤។ លោកបានចូលរួមក្នុងការប្រកួតជើងឯកថ្នាក់ជាតិនៃអ្នកជំនាញខាងសម្ភារៈបរិក្ខារ ក្នុងកម្មវិធីទូរទស្សន៍ដ៏ពេញនិយម "TV Champion(ជើងឯកទូរទស្សន៍)" ហើយបានឈ្នះចំនួនបីដងជាប់ៗគ្នា ដែលធ្វើអោយគាត់ទទួលបានហេស្សនាមថា "ស្ដេចសម្ភារៈការិយាល័យ"។ បន្ទាប់ពីធ្វើការជាអ្នករៀបចំផែនការផលិតផល និងទីផ្សារនៅក្រុមហ៊ុនផលិតសម្ភារៈការិយាល័យ Sun-Star Stationery Co., Ltd. អស់រយៈពេល១៣ឆ្នាំ លោកបានចូលនិវត្តន៍ ហើយបានចុះកិច្ចសន្យាជាអ្នកជំនាញឯករាជ្យជាមួយក្រុមហ៊ុន។ លោកគឺជានិពន្ធនាយកនៃគេហទំព័រសម្ភារៈការិយាល័យ " Bungu no Tobira ( ទ្វារនៃសម្ភារៈការិយាល័យ)" និងជា YouTuber ដែលផ្ដោតលើសម្ភារៈការិយាល័យផងដែរ។*

ទំព័រទី១០៖

## កន្លែងដែលនាំឱ្យអ្នកកាន់តែចង់សរសេរ

*ផ្លាស់ប្ដូរបរិយាកាស ធ្វើឱ្យអ្នកអាចផ្ដោតអារម្មណ៍បាន។*

*កន្លែងពិសេស ដែលគ្រាន់តែអ្នកអង្គុយចុះ ចង់សរសេរតែម្ដង។*

### តុដ៏វែងមួយនៅក្នុងហាងសៀវភៅដែលអ្នកអាចចំណាយពេលខ្លះមុនពេលចេញដំណើរ

Haneda Airport Tsutaya Bookstore(ហាងសៀវភៅត្ស៊ុតាយ៉ានៅក្នុងអាកាសយានដ្ឋានហាណិដា) គឺជាកន្លែងស្ងប់ស្ងាត់ និងស្ងៀមស្ងាត់នៅកណ្ដាលអាកាសយានដ្ឋានដ៏មមាញឹក។ ហាងនេះមានសៀវភៅជាច្រើនជម្រើស ចាប់ពីសៀវភៅណែនាំអំពីវប្បធម៌ជប៉ុន រហូតដល់រឿងប្រលោមលោក និងម៉ានហ្គា ដូច្នេះអ្នកអាចអានវាយឺតៗ មួយៗ នៅតុវែងនៅចំកណ្ដាល។ ដោយសារតុដ៏វែងនេះអាចប្រើប្រាស់បានដោយសេរី អ្នកដំណើរដែលជាអ្នកជំនួញជាច្រើនប្រើវាដើម្បីបើកសៀវភៅកត់ត្រារបស់ពួកគេ ដើម្បីរៀបចំកាលវិភាគរបស់ពួកគេ និងប្រមូលផ្ដុំគំនិតមុនពេលឡើងយន្តហោះ។ អ្នកក៏អាចយកភេសជ្ជៈពីហាងកាហ្វេនៅក្បែរនោះមកជាមួយបានផងដែរ។ វាជាកន្លែងដ៏ប្រណិតមួយដែលអ្នកអាចសម្រាក និងដកខ្លួនអ្នកចេញពីភាពអ៊ូអរ។

*រូបខាងលើ៖ តុវែងដែលនៅជុំវិញហ៊ុំព័ទ្ធដោយទូសៀវភៅ*

*រូបខាងក្រោម៖ ការរីករាយនឹងការសរសេរបណ្ដើរមើលទិដ្ឋភាពយន្តហោះនៅខាងក្រៅបណ្ដើរ។*

*រូបថត៖ គុរីហារ៉ា អុសាមុ*

ទំព័រទី១១៖

### ហាង ហ្សាកកា (បណ្ណាគារខ្នាតតូច) ដែលមានតុសម្រាប់សរសេរសំបុត្រ

ប្រសិនបើអ្នកកំពុងស្វែងរកកន្លែងអង្គុយ និងសរសេរសំបុត្រដោយមិនប្រញាប់ប្រញាល់នោះ អ្នកគួរទៅ"Post-sha" ដែលជាប្រភេទហាងហ្សាកកា(បណ្ណាគារខ្នាតតូច) នៅអូសាកា ដែលមានលក់ទំនិញប្លែកៗ ដូចជាសម្ភារៈការិយាល័យ និងសៀវភៅរូបភាព។ ហាងនេះមានលក់ក្រដាស និងស្រោមសំបុត្រចំនួន៣០ប្រភេទ។ ប្រសិនបើអ្នកបានទិញក្រដាសសរសេរសំបុត្រនៅទីនោះ អ្នកអាចខ្ចីប៊ិកមួយពីហាង ដែលជាប៊ិកកែវ ប្រើដោយជ្រលក់ជាមួយទឹកថ្នាំ។ អ្នកគ្រាន់តែអង្គុយសរសេរនៅតុឈើដែលមានទីតាំងក្បែរមាត់បង្អួច ហើយពេលអ្នកសរសេរដោយមើលទៅដើមឈើក្នុងឧទ្យាន និងទេសភាពទីក្រុង នោះអារម្មណ៍របស់អ្នកនឹងចូលទៅក្នុងសំបុត្រដោយធម្មជាតិ។

*រូបខាងលើ៖ កំពុងអង្គុយសរសេរសំបុត្រនៅតុក្នុងហាងហ្សាកកា(បណ្ណាគារខ្នាតតូច)។*

*រូបក្រោមខាងឆ្វេង៖ ក្រដាស និងស្រោមសំបុត្រដើម(អូរីជីណល) របស់ហាងPost-sha*

*រូបក្រោមខាងស្ដាំ៖ ប៊ិចកញ្ចក់ដែលអាចទិញបាននៅក្នុងហាង*

*រូបថត៖ យ៉ាម៉ាហ្គឹឈិ ស៊ីនអ៊ិឈិ*

## រ៉ុកាន ដែលអ្នកគ្រប់គ្នាអាចទទួលអារម្មណ៍ផ្ដោតដូចជាអ្នកនិពន្ធ

នៅប្រទេសជប៉ុន នៅពេលដែលអ្នកនិពន្ធជាប់គាំងក្នុងការសរសេរ ហើយដួលបន្ទប់មួយនៅរ៉ុកាន(ផ្ទះសំណាក់បែបជប៉ុន) ឬសណ្ឋាគារ ស្នាក់នៅដើម្បីផ្ដោតអារម្មណ៍លើការសរសេរនោះ ត្រូវបានគេហៅថា "កានហ្សុំម៉ិ"។ នៅទីក្រុងតូក្យូ មាន "ហូមេកាន" គឺជាផ្ទះសំណាក់ពិសេសមួយដែលអ្នកអាចទទួលបទពិសោធបែប"កានហ្សុំម៉ិ"។ អគារនេះត្រូវបានគេនិយាយថា មានបន្ទប់បែបជប៉ុនដ៏សាមញ្ញ និងប្រណិត ត្រូវបានអ្នកនិពន្ធពិតៗប្រើកាលពីអតីតកាល ហើយនៅពេលអ្នកលាតក្រដាសប៉ារ៉ូរឿងរបស់អ្នកនៅលើតុឈើដើម្បីសរសេរនោះ អ្នកប្រាកដជាមានអារម្មណ៍ដូចជាអ្នកជំនាញអក្សរសាស្ត្រ។

*រូបខាងឆ្វេង៖ មានអារម្មណ៍ដូចជាអ្នកនិពន្ធកំពុងអង្គុយសរសេរប៉ារ៉ូរឿង។*

*រូបខាងស្ដាំ៖ ហូមេកាន សាងសង់ក្នុងឆ្នាំ១៨៩៨*

*រូបថត៖ គុរីហារ៉ា អុសាមុ*

<u>ទំព័រទី១២</u>៖

# ការលេខពណ៌ដ៏រីករាយ

*Inkstandស្ថិតនៅជាន់ទី២នៃហាងលក់សម្ភារៈការិយាល័យកាមិម៉ុរី។បុគ្គលិកមានភាពរួសរាយរាក់ទាក់ និងយកចិត្តទុកដាក់ចំពោះអតិថិជន។*

## បង្កើតពណ៌មានតែមួយនៅក្នុងពិភពលោក៖

## អ៊ីនគីស្ដានដុ (Inkstand)

អ៊ីនគីស្ដានដុ(Inkstand) ស្ថិតនៅក្នុងហាងលក់សម្ភារៈការិយាល័យមួយ ដែលអាចផ្ដល់នូវទឹកប៊ិកតាមតម្រូវការអតិថិជន ដែលស្ថិតនៅក្នុងសង្កាត់គុរ៉ាម៉ាអិ នៅជិតអាសាគុសា ដែលជាកន្លែងទេសចរណ៍ដ៏ពេញនិយមបំផុតមួយរបស់ទីក្រុងតូក្យូ។

អតិថិជនជ្រើសរើសពីពណ៌សរុបចំនួន១៨ប្រភេទ រួមមានទឹកថ្នាំពណ៌ដើមមាន១៤ពណ៌ ក៏ដូចជាពណ៌ក្រហម ខៀវ និងខ្មៅ បន្ថែមនូវសារធាតុរាវស្រាល ហើយលាយតាមរូបមន្តផ្ទាល់ខ្លួន ដោយបន្ថែមទឹកថ្នាំពណ៌ម្ដងមួយតំណក់ៗ ទៅក្នុងទឹកថ្នាំដែលលាយនោះ។ អតិថិជនត្រូវកត់ត្រា ពណ៌ និងចំនួនដំណក់ទឹកថ្នាំដែលប្រើនៅពេលបន្ថែម បន្ទាប់មកបុគ្គលិក Inkstand ប្រើរូបមន្តនេះ ដើម្បីលាយពណ៌មួយប្រភេទ ហើយដាក់វាទៅក្នុងដបទឹកថ្នាំពិសេស។ សេវាកម្មផលិតទឹកថ្នាំផ្ទាល់ខ្លួននេះបានរីកចម្រើន

ដោយកើតចេញពីសំណើជាច្រើនរបស់អតិថិជន ដែលចង់បានពណ៌នេះលាយជាមួយពណ៌នោះ និងចង់បានពណ៌ផ្សេងៗជាច្រើនទៀត ទើបហាងសម្រេចលក់ទឹកថ្នាំដែលអតិថិជនបង្កើតតែម្តង។

ដំបូងឡើយ ហាងបានប្រើទឹកថ្នាំលាយពណ៌ដែលរលាយក្នុងទឹក ដើម្បីជ្រាបចូលទៅក្នុងក្រដាសបានល្អ ប៉ុន្តែបញ្ហានោះគឺវាងាយប្រតាក ហើយពណ៌ក៏ហើរលឿន។ សម្រាប់ដំណោះស្រាយ ហាងបានបញ្ជាទិញជាពិសេស ទៅកាន់ក្រុមហ៊ុនផលិតទឹកថ្នាំ ដើម្បីបង្កើតទឹកថ្នាំពណ៌ផ្ទាល់ខ្លួន ដែលមិនត្រូវបានប្រើប្រាស់ជាទូទៅនៅក្នុងឧបករណ៍សរសេរនោះទេ។ Inkstand បានបង្កើតទឹកថ្នាំដ៏ល្អបំផុតមួយដែលផ្តល់ពណ៌រស់រវើក ជាប់បានយូរ និងមិនសូវងាយស្ទះចុងប៊ិក។

ជាគោលការណ៍ ចំនួនទឹកថ្នាំដែលត្រូវលាយបញ្ចូលគ្នាកំណត់ត្រឹមបីពណ៌ ហើយលើសពីនេះ នឹងប្រែជាពណ៌ខ្មៅ និងភក់។ ប្រសិនបើអ្នកចង់បន្ថែមភាពរស់រវើកនៃពណ៌ សូមបន្ថែមនូវសារធាតុរាវស្រាល។ ការលាយពណ៌ និងពន្លឺពណ៌ គឺជាដំណើរការសាកល្បង និងកំហុស ដែលនាំឱ្យពណ៌ដ៏ប្រណិតមួយ មិនត្រូវបានរកឃើញនៅក្នុងផលិតផលពាណិជ្ជកម្ម។ Inkstand ទទួលបានកេរ្តិ៍ឈ្មោះជាកន្លែងផ្តល់នូវអនុស្សាវរីយ៍ពេលធ្វើដំណើរកំសាន្តដែលមិនអាចបំភ្លេចបាន ហើយឥឡូវនេះជាទិសដៅសម្ភារៈការិយាល័យដែលទាក់ទាញអ្នកគាំទ្រមកពីជុំវិញពិភពលោក។

*រូបខាងលើ៖ អតិថិជនបង្កើតទឹកថ្នាំផ្ទាល់ខ្លួន ដោយធ្វើតេស្តប្រើ ត៊ីកិពេន (ប៊ិកជ្រលក់ពណ៌) ដើម្បីពិនិត្យមើលនៅពេលពួកគេលាយពណ៌។*

*រូបខាងស្តាំ៖ ទឹកថ្នាំដើម (អូរីជីណាល) ដែលមានតែមួយ ត្រូវបានដាក់ក្នុងដបកែវ។*

<u>ទំព័រទី១៣៖</u>

មន្ទីរពិសោធន៍មួយដែលអ្នកអាចបង្កើតពណ៌ទឹកថ្នាំផ្ទាល់ខ្លួន ដែលពណ៌ប្រេងប៉ាស្តែល ឬប្រេងចម្រុះបានទាក់ទាញទាំងកុមារ និងមនុស្សពេញវ័យ។ នេះគ្រាន់តែជាឧទាហរណ៍ពីរ នៃចំណង់ចំណូលចិត្តរបស់ប្រជាជនជប៉ុនសម្រាប់ពណ៌ដែលកើតចេញពីការខិតខំប្រឹងប្រែងមិនចេះចប់របស់ពួកគេក្នុងការគូររូប និងគំនូរ។

## រៀនប្រើពណ៌៖ ពណ៌ប្រេងចម្រុះ

ពណ៌ប្រេងចម្រុះ គឺជាពណ៌សិល្បៈពេញនិយមជាងគេសម្រាប់កុមារនៅជប៉ុន។ ជាការពិត មានផលិតផលពណ៌ប្រេងចម្រុះជាច្រើន ហើយពណ៌ប្រេងចម្រុះដែលផលិតដោយរោងចក្រផលិតសម្ភារៈសិល្បៈមួយជាពិសេសដែលមានទីតាំងនៅអូសាកា មានប្រវត្តិផលិតពណ៌ប្រេងចម្រុះជាយូរឆ្នាំសម្រាប់កុមារជប៉ុន ប្រហែលជាង១០០ឆ្នាំមកហើយ។ អាថ៌កំបាំងដែលធ្វើឱ្យពណ៌ប្រេងចម្រុះរបស់ពួកគេពេញនិយមគឺវាត្រូវបានផលិតឡើងយ៉ាងរឹងមាំ មិនជាប់ស្អិត និងជាគុណភាពទៀនដែលងាយកាន់ ព្រមទាំងងាយផាត់ពណ៌ប្រេងចម្រុះបញ្ចូលគ្នា។

ពណ៌ប្រេងចម្រុះ គឺត្រូវបានបង្កើតឡើងដោយសារធាតុពណ៌ ក្រមួន និងប្រេងរាវ។ សារធាតុពណ៌ ត្រូវបានលាយជាមួយក្រមួនដែលរលាយ ហើយចាក់ប្រេងរាវចូល។ ការលាយបញ្ចូលគ្នាឱ្យសព្វ ហើយក្រោយមកចាក់ក្នុងពុម្ព និងត្រូវរក្សាទុកឱ្យត្រជាក់ កករឹងជាការស្រេច។ នៅឆ្នាំ២០១១ ដើម្បីចូលរួមអបអរសាទរខួបលើកទី៩០របស់ក្រុមហ៊ុនផលិតពណ៌ប្រេងចម្រុះមួយដ៏ល្បីល្បាញ

ក្រុមហ៊ុននោះបានបង្កើតពណ៌ប្រេងចម្រុះ៧០០មុខផ្សេងៗគ្នា ក្នុងឱកាសនោះផងដែរ។ ក្នុងការស្រាវជ្រាវដើម្បីផលិតពណ៌ប្រេងចម្រុះថ្មីនេះ សិប្បករផលិតមកពីវិទ្យាស្ថានស្រាវជ្រាវរបស់ក្រុមហ៊ុន ដំបូងបានសាកល្បងបង្កើតពណ៌ប្រេងចម្រុះថ្មីប្រហែលជា ២១០០ពណ៌ ដោយយកចិត្តទុកដាក់យ៉ាងខ្លាំងលើចំណាត់ថ្នាក់ទម្រង់ពណ៌ស្រមោលប្រដេញ។ ដោយសារតែភាពខុសប្លែកគ្នានៃពណ៌ប្រេងចម្រុះទាំងនេះ គឺពិបាកមើលឃើញដោយភ្នែកទទេនោះ គេប្រើវិធីតំរៀបពណ៌ប្រដេញជាបីចំណាត់ថ្នាក់នៃពណ៌ដើម។

ជ្រុងមួយផ្សេងទៀតនៃសម្ភារៈសិល្បៈដែលបង្កើតឡើងសម្រាប់កុមារ គឺគេប្រើឈ្មោះប្រពៃណីជប៉ុនសម្រាប់ហៅពណ៌ប្រេងចម្រុះនីមួយៗដែលពាក់ព័ន្ធនឹងធម្មជាតិ ដើម្បីបង្ហាត់បង្រៀនកុមារអំពីពណ៌ប្រេងចម្រុះនេះ។ ជាឧទាហរណ៍ ពណ៌ប្រេងរាងពណ៌ទឹកក្រូចខ្ចី ត្រូវបានគេហៅថា ដាអ៊ិដាអ៊ិ អ៊ីរ៉ុ ដែលមានប្រភពពីឈ្មោះក្រូចលឿងជប៉ុន។ ពណ៌ក្រហមបែកលឿងស្រអាប់ ដូចពណ៌ច្រែះ ត្រូវបានគេហៅថា គុឈិបា អ៊ីរ៉ុ ដែលវាមានភាពស្រដៀងគ្នាទៅនឹងពណ៌ស្លឹកឈើជ្រុះ។ ការធ្វើបែបនេះ កុមារជប៉ុន អាចទទួលបានបទពិសោធន៍ពីវប្បធម៌របស់ពួកគេតាមរយៈការរៀនពណ៌ដោយមិនដឹងខ្លួន។

*រូបខាងលើ៖ Cray-Pas ធ្វើពីសាធាតុពណ៌ទាំងធម្មជាតិ និងសំយោគ*

*រូបខាងក្រោម៖ នៅរោងចក្រមួយ បានកាត់ល្បាយដែលហៀរចេញពីពុម្ព ហើយសំណល់ដែលហៀរចេញ ត្រូវលាយបញ្ចូលជាល្បាយឡើងវិញ ដើម្បីបង្កើតពណ៌ប្រេងចម្រុះ។ (រូបថត៖ SAKURA COLOR PRODUCTS CORPORATION)*

*រូបខាងឆ្វេង៖ Cray-Pas® ដែលផលិតដោយ SAKURA COLOR PRODUCTS CORPORATION។ ឈ្មោះCray-Pas® គឺមានលក្ខណៈរួមបញ្ចូលគ្នាពីគ្រូលីទាន និងពណ៌ចម្រុះ។*

*រូបខាងស្តាំ៖ Cray-Pas® ចំនួន៧០០ពណ៌ ត្រូវរក្សាទុកក្នុងប្រអប់អាគ្រីលិក។ ភាពខុសគ្នានៃពណ៌ចម្រុះដែលត្រូវបានបែងចែកយ៉ាងលម្អិតនេះ ត្រូវអរគុណចំពោះ កែវភ្នែករបស់អ្នកស្រាវជ្រាវរបស់ក្រុមហ៊ុន ដែលបានលាយបញ្ចូលសារធាតុពណ៌នានាដោយដៃ។ (រូបថត៖ SAKURA COLOR PRODUCTS CORPORATION)*

<u>ទំព័រទី១៤៖</u>

*វិចិត្រករម៉ានហ្គា តាណាកា តិកុ គូសគំនូរព្រាងដោយខ្មៅដៃ។ ដើម្បីបង្កើតគំនូរម៉ានហ្គា នាងប្រើប្រាស់ឧបករណ៍ប៊ីនហ្គី (ប៊ិក ខ្មៅដៃ ក្រដាស ជាដើម) និងឧបករណ៍ឌីជីថល។*

*រូបថត៖ គុរីហារ៉ា អុសាមុ*

*សហការដោយ៖ Wacom*

## ឧបករណ៍ដែលវិចិត្រកររម៉ានហ្គាពេញចិត្ត

តើគេប្រើឧបករណ៍អ្វីដើម្បីបង្កើតគំនូរម៉ានហ្គា? ស្វែងយល់ពីឧបករណ៍ដែលវិចិត្រករអាជីពប្រើ និងរបៀបប្រើប្រាស់ដើម្បីបង្កើតគំនូរម៉ានហ្គា។

មានអ្នកអាននៅជុំវិញពិភពលោក រីករាយនឹងការអានសៀវភៅរូបថ្លុក ឬ ម៉ានហ្គា។ ប៉ុន្មានឆ្នាំនេះ គំនូរម៉ានហ្គា ត្រូវបានគូរដោយវិចិត្រករនានាដែលពឹងស្ទើរតែទាំងស្រុងទៅលើឧបករណ៍ឌីជីថល។ ក៏ប៉ុន្តែនៅតែមានវិចិត្រករមួយចំនួន បង្កើតរូបទាំងនោះលើក្រដាស ដោយប្រើប៊ិក ក្រដាស និងទឹកថ្នាំពណ៌នានាសម្រាប់ការបង្កើតគំនូរម៉ានហ្គា ចាប់ពីការគូរព្រាង រហូតដល់គំនូរសម្រេច។ លើសពីនេះ ក្រុមវិចិត្រករខ្លះ ជ្រើសរើសយកជម្រើសទាំងពីរ ទាំងការប្រើឧបករណ៍ប៊ឺនហ្គី (ប៊ិក ខ្មៅដៃ ក្រដាសជាដើម) និងការប្រើឧបករណ៍ឌីជីថលដើម្បីសម្រេចការងាររបស់ពួកគេ។

ចំណង់ចំណូលចិត្តមួយរបស់វិចិត្រករម៉ានហ្គាដែលមិនបានផ្លាស់ប្តូរតាំងពីមុនរហូតមកទល់ឥឡូវ គឺការប្រើប្រាស់ ត្សឺកិពេន(ប៊ិកជ្រលក់ពណ៌) ដែលមានចុងប៊ិកជ្រលក់ទៅក្នុងក្រឡថ្នាំពណ៌។ ប៊ិកជ្រលក់ពណ៌ គឺចាំបាច់ក្នុងដំណើរការជ្រលក់ពណ៌ លាបពណ៌លើគំនូរដែលវិចិត្រករបានគូរព្រាងដោយខ្មៅដៃ។ ក្នុងចំណោមចុងប៊ិកទាំងអស់ មានតែចុងប៊ិកជីពេន(G-pen)ទេ តែងត្រូវបានប្រើដើម្បីគូសខ្សែដានជាគំនូសជុំវិញរូបដោយសារតែចុងប៊ិកនេះមានរាងស្រួច មានរន្ធបង្ហូរចុះក្រោម និងមានលទ្ធភាពដែលអាចគូសឱ្យខ្សែដានក្រាស ឬ ស្តើងអាស្រ័យលើកម្លាំងសង្កត់។ ចំណែកឯប៊ិកម៉ារឺពេន(Maru-pen) ក៏ត្រូវបានប្រើសម្រាប់គូសខ្សែញឹក ដូចជាត្រង់ភ្នែក សក់ និងផ្ទៃខាងក្រោយ។ អ្វីក៏ដោយដែលវិចិត្រករម៉ានហ្គាបានជ្រើសរើសប្រើប្រាស់ គឺពួកគេជឿថា មានតែការគូរដោយដៃផ្ទាល់ទេដែលអាចបង្កើតបានតួអង្គនានាជាមួយនឹងដួងព្រលឹងរបស់ពួកគេ ហើយវិចិត្រករទាំងនោះពិតជាជ្រើសរើសជាពិសេសទៅលើការប្រើប្រាស់ឧបករណ៍របស់ពួកគេដោយជ្រើសរើសយ៉ាងហ្មត់ចត់លើក្បាលប៊ិក ក្រឡទឹកថ្នាំពណ៌ ខ្មៅដៃ និងថ្នាំពណ៌ដែលគេប្រើ។

វត្តមាននៃឧបករណ៍កុំព្យូទ័រ ដែលភ្ជាប់ជាមួយអេក្រង់LCD និងជាមួយប៊ិកឌីជីថល បានបង្កើតឱកាសថ្មីក្នុងការបង្ហាញរូបរាងម៉ានហ្គា។ ស្រដៀងគ្នាទៅនឹងការប្រើប្រាស់ប៊ិក និងក្រដាសដែរ ការប្រើប៊ិកឌីជីថល ក៏ត្រូវផ្សារភ្ជាប់នឹងរបៀបគូរសង្កត់ ដែលអាចឱ្យអ្នក គូរខ្សែគំនូសនានា និងបន្ថែមពណ៌ដូចដែលគេប្រើប៊ិកគូរគំនូរដោយដៃផ្ទាល់ដែរ។ វិចិត្រករអាចជ្រើសរើសពណ៌មួយក្នុងចំណោមរាប់លានពណ៌ ហើយផ្ទៃខាងក្រោយអាចផ្លាស់ប្តូរដោយការទាញយករូបផ្ទៃដែលមានស្រាប់ ឬ ការបង្កើតផ្ទៃខាងក្រោយជាមួយនឹងក្បាច់ក្រឡានានាដោយខ្លួនឯង។

ចាប់ពីគំនូរគ្រោងសាច់រឿង រហូតដល់គំនូរសម្រេច របៀបបង្កើតសៀវភៅរូបថ្លុក ឬ ម៉ានហ្គា មិនមែនជារឿងងាយស្រួលទេ។ ម៉ានហ្គា នឹងបន្តវិវត្តទៅមុខ ស្របពេលដែលវិចិត្រករម៉ានហ្គាទាញប្រយោជន៍ពីការប្រើប្រាស់ទាំងឧបករណ៍ប៊ឺនហ្គី (ប៊ិក ខ្មៅដៃ ក្រដាសជាដើម) និងឧបករណ៍ឌីជីថល។

<u>ទំព័រទី១៥៖</u>

*តាណាកា តិកុ បង្ហាញជំហ៊ាននីមួយៗក្នុងដំណើរការបង្កើតរូបគំនូរម៉ានហ្គា។ នាងប្រើខ្មៅដៃចុច(២)បណ្តូលពណ៌ខៀវ(១) ដើម្បីគូសព្រាងគំនូរដំបូង ដែលនឹងមើលមិនឃើញទេនៅពេលព្រីនគំនូរព្រាងនោះ។ បន្ទាប់មក នាងប្រើខ្មៅដៃ(៣) ដើម្បីដានលើគំនូរព្រាងនោះ(៤)។*

*បន្ទាប់មក នាងជ្រលក់ពណ៌ គូសដានលើខ្សែសំខាន់ៗ។ នាងប្រើប៊ិកជីពេន(G-pen)(៥) និងប៊ិកម៉ារ៉ូពេន(Maru-pen)(៦) ដោយជ្រលក់ចុងប៊ិក ក្នុងក្រឡទឹកថ្នាំពណ៌(៧) ហើយគូសដាន(៨)។ នាងជ្រើសរើសតែចុងប៊ិកខាងស្តាំប៉ុណ្ណោះ ដែលអាចគូសខ្សែដែលក្រាស់ៗ។ នេះគឺជាពេលវេលាដែលតានតឹង ដោយសារតែការគូរដោយដៃបែបនេះ មិនអាចកោសលុបបានទេ។*

*ចំណែកការដាក់ពណ៌វិញ គឺអាចធ្វើឡើងតាមឧបករណ៍គូរ LCD(៩)។ គំនូរដែលគូរដោយដៃត្រូវយកទៅស្កេន បានជារូបឌីជីថល ហើយនាងប្រើប៊ិកឌីជីថលដើម្បីដាក់ពណ៌(១០)។ នាងជ្រើសរើសពណ៌ចេញពីតារាងពណ៌ និងប្រើកម្មវិធីជក់ (brush tool) ដើម្បីងាយបង្កើតរូបព្រាល និងបង្កើតរូបមានលក្ខណៈពិសេសនានា(១១)។ ចុងក្រោយ រូបភាពដែលមានពណ៌ដ៏រស់រវើក បានលេចចេញជារូបរាង។*

***គុណប្រយោជន៍នៃការគូរដោយដៃ និងការគូរតាមឧបករណ៍ឌីជីថល***

*ទិន្នន័យឌីជីថល គឺធ្វើឱ្យមានភាពងាយស្រួលក្នុងការចែករំលែក និងផ្តល់នូវអារម្មណ៍សុវត្ថិភាពដោយសារតែវិចិត្រករអាចលុប ឬ ត្រលប់មករករូបដើម ប្រសិនគេបង្កើតកំហុស។ តែផ្ទុយទៅវិញ នៅពេលគូរលើក្រដាស គំនូសនីមួយៗមិនអាចកោសលុបបានទេ ដែលវាបានផ្តល់នូវថាមពល និងកម្លាំងដល់គំនូស។ មិនថាវិចិត្រករប្រើឧបករណ៍បឺនហ្គី (ប៊ិក ខ្មៅដៃ ក្រដាសជាដើម) ឬ ឧបករណ៍ឌីជីថលនោះទេ ការអនុវត្តម្តងហើយម្តងទៀតគឺមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការធ្វើឱ្យមានភាពស្ទាត់ជំនាញនៃទឹកដៃរបស់ពួកគេ។ (ដកស្រង់ចេញពីបទសម្ភាសន៍ជាមួយសិល្បករម៉ានហ្គា តាណាកា តិកុ) ©Teko Tanaka 2024*

*សៀវភៅរូបថ្លុក ឬ ម៉ានហ្គា ដោយតាណាកា តិកុ*

*ហុកាហ្គុ ប៉ុនីថិរុ ("Ponytail After School")*

*(ក្រុមហ៊ុន Margaret Comics, Shueisha Inc.)*

<u>ទំព័រទី១៦៖</u>

## ដំណើរកំសាន្តនិម្មិតទូទាំងប្រទេសជប៉ុន៖ សម្ភារៈការិយាល័យក្នុងតំបន់

សិប្បកម្មដែលត្រូវបានបន្សល់ទុកនៅតាមតំបន់ តាំងពីបុរាណកាលជាច្រើនជំនាន់ ក៏ដូចជាសម្ភារៈដែលរចនាតាមរូបភាព ឬទេសភាពជាក់ស្តែងក្នុងតំបន់។ សូមស្វាគមន៍មកកាន់ដំណើរកំសាន្តតាមសន្លឹកទស្សនាវដ្តីដែលអ្នកកំពុងអាន ដើម្បីស្វែងរកសម្ភារៈការិយាល័យដែលមានការឆ្លុះបញ្ចាំងពីលក្ខណៈពិសេសនៃតំបន់ទាំងនោះ។

### ខេត្តស៊ីហ្គា៖ បន្ទាត់ដែលមានការរចនារូបបឹងប៊ីវ៉ា

អ្នកអាចគូររូបបឹងប៊ីវ៉ា ដែលជាបឹងធំជាងគេរបស់ជប៉ុន ក្នុងទំហំប្រហែល ១ភាគ១លាន ដោយប្រើបន្ទាត់នេះ។ ជាមួយរូបស្រមោលសត្វនានា ដែលរស់នៅក្នុងបឹងប៊ីវ៉ា ប្រាសាទនានា និងអ្វីៗដែលនៅក្បែរតំបន់ទេសចរណ៍នោះ អាចបង្កើតការចងចាំមួយយ៉ាងសប្បាយរីករាយក្នុងដំណើរកំសាន្តរបស់អ្នកនៅទីនោះ។ *រូបថត៖ គំនូរបឹងប៊ីវ៉ា ដោយក្រុមហ៊ុន KOKUYO Product Shiga Co., Ltd.*

### ខេត្តហ៊ីរ៉ូស៊ីម៉ា៖ ម៉ូហ៊ិតស៊ឺ (ជក់)

គឺម៉ាណុចូ (ទីក្រុងគឺម៉ាណុ) ក្នុងខេត្តហ៊ីរ៉ូស៊ីម៉ា ដែលមានយ៉ាងហោចណាស់ម្នាក់ក្នុងចំណោមដប់នាក់ ធ្វើការពាក់ព័ន្ធនឹងការបង្កើតជក់ ហើយក៏ជាកន្លែងដែលគេស្គាល់ថា ជារាជធានីជក់នៃប្រទេសជប៉ុន។ សរសៃជក់ដ៏ប្រណិតនៃគឺម៉ាណុចូ ត្រូវបានបង្កើតឡើងដោយសិប្បករជើងចាស់។ គេតែងតែស្វែងរកជក់បែបនេះសម្រាប់ការគូរគំនូសបន្ទាត់ច្បាស់ និងលម្អិត។ មិនត្រឹមតែជក់គំនូរប៉ុណ្ណោះទេ ជក់គ្រឿងសម្អាងដែលត្រូវបានបង្កើតឡើងដោយវិធីសាស្ត្របែបនេះ ក៏ពេញនិយមនៅក្រៅស្រុកផងដែរ។ *រូបថត៖ ហ្វូជិណុសាតូ កុបុ*

### ខេត្តណាហ្គាសាគី៖ ទឹកថ្នាំពណ៌ក្នុងស្រុក

ទឹកថ្នាំពណ៌ក្នុងក្រឡរចនាដោយរូបវត្ថុប្រចាំតំបន់ និងទេសភាពរបស់ខេត្តណាហ្គាសាគី អាចជាវត្ថុអនុស្សាវរីយ៍ដ៏ល្អបំផុតមួយ។ ក្រឡទឹកថ្នាំនេះ មានរូបកោះគុជុគុ ដែលជាកោះល្បីមួយប្រជុំទៅដោយព្រៃខៀវស្រងាត់ និងទឹកស្ងប់។

*រូបថត៖ Nagasaki Bikei Ink Kujukushima Islands Green ដោយ Ishimaru Bunkoudou*

### ខេត្តកូឈិ៖ វ៉ាតុជិ-ណាតុ(សៀវភៅសរសេរប្រពៃណីជប៉ុន)

សៀវភៅសរសេរទាំងនេះត្រូវបានបង្កើតឡើងដោយវិធីសាស្ត្រការដេរថ្នេរញឹកភ្ជាប់ដោយប្រុងប្រយ័ត្ន។ សៀវភៅទាំងនេះ ស្រស់ស្អាតខ្លាំងណាស់ ដោយមើលទៅមិនមានការបិតភ្ជាប់ដោយប្រើកាវគីមី ហើយការដេរដោយថ្នេរបែបនេះគឺមិនងាយដាច់នោះទេ។ វិធីសាស្ត្រដេរសៀវភៅប្រកបដោយគុណតម្លៃបែបនេះ គឺនៅតែត្រូវបានអនុវត្តនៅក្នុងខេត្តកូឈិ ជាទីតាំងដែល ក្រដាសតុសាវ៉ាស៊ិ ត្រូវបានបង្កើតឡើង។

*រូបថត៖ Kochi Seihon*

ទំព័រទី១៧៖

### ខេត្តអ៊ីស៊ីកាវ៉ា៖ ម៉ានេនហិត្សឺ (ប៊ិកប៉ាកកា) បិតសន្លឹកមាស

ប៊ិកប៉ាកកាបិតសន្លឹកមាស គឺជាប៊ិកប្រេននាំមុខគេមួយរបស់ជប៉ុន ដែលត្រូវបានបង្កើតឡើងដោយមានការសហការពីសិប្បករសន្លឹកមាស នៅទីក្រុងកាណាហ្សាវ៉ា ក្នុងខេត្តអ៊ីស៊ីកាវ៉ា។ វាផ្តោតលើសិល្បៈប្រពៃណីជប៉ុន ដោយគំនូរសម្រស់ធម្មជាតិ ជាមួយការប្រើប្រាស់សន្លឹកមាស និងសម្ភារៈដទៃទៀត។

*រូបថត៖ ក្រុមហ៊ុន Hakuichi Co., Ltd.,Kanazawa gold leaf fountain pen by PLATINUM PEN CO., LTD.*

### ខេត្តអាអុម៉ូរី៖ ហ្គាវ៉ាស៊ុពេន(ប៊ិកកញ្ចក់) និងក្រឡទឹកថ្នាំកញ្ចក់រាងដូចផ្លែប៉ោម

ក្រឡទឹកថ្នាំកញ្ចក់រាងដូចផ្លែប៉ោម គឺជាឯកទេសមួយប្រចាំខេត្តអាអុម៉ូរី (រូបឆ្វេង) ក៏ដូចជាប៊ិកកញ្ចក់ដែលមានរាងផ្លែប៉ោមនៅក្បាលប៊ិក (រូបស្តាំ)។ ប៊ិកកញ្ចក់ គឺជាប៊ិកដែលមានដើមកំណើតនៅជប៉ុន ជាប៊ិកដែលអាចបឺតទឹកថ្នាំតាមចុងប៊ិកដែលថ្លាដូចកញ្ចក់នៅផ្នែកខាងស្តាំ។

*រូបថត៖ Tsugaru Vidro*

### រាជធានីតូក្យូ៖ ម៉ាគិហ្គាមិ(ក្រដាសរមូរ)

កាលដើមឡើយនៅប្រទេសជប៉ុន សំបុត្រ និងឯកសារនានា ជានិច្ចជាកាល ត្រូវសរសេរដោយជក់ និងទឹកថ្នាំ លើក្រដាសវ៉ាស៊ិរមូររបស់ជប៉ុន។ រូបដែលបង្ហាញនៅទីនេះ គឺជាក្រដាសវ៉ាស៊ិរមូរប្រាំពណ៌ ដែលត្រូវបានអ៊ុតដើម្បីការពារការជ្រាបធ្លុះធ្លាយនៅពេលសរសេរដោយប៊ិក។ ក្រដាសរមូរនេះ ជាផលិតផលដ៏ពេញនិយមពីហាងសម្ភារៈការិយាល័យបុរាណ ដែលមានលក់ផលិតផលក្រដាសវ៉ាស៊ី និងផលិតផលក្រដាសផ្សេងទៀត អស់រយៈពេលជាង២០០ឆ្នាំមកហើយ។ *រូបថត៖ Gounsen by Haibara*

### ខេត្តក្យូតុ៖ ហ្គូស្ស៊ុអ៊ីនចូ (សៀវភៅបោះត្រា ហ្គូស្ស៊ុអ៊ីន)

ភ្ញៀវទេសចរទៅកាន់ព្រះវិហារ និងវត្តនានាក្នុងប្រទេសជប៉ុន អាចទទួលបាននូវត្រាក្រហម ហ្គូស្ស៊ុអ៊ីន ដែលមានសរសេរឈ្មោះព្រះវិហារ ឬ វត្តនោះ និងកាលបរិច្ឆេទនៃការមកកាន់ទីនោះ។ មានព្រះវិហារ និងវត្តជាច្រើនផ្តល់ជូននូវ ហ្គូស្ស៊ុអ៊ីនចូ ជាសៀវភៅធ្វើពីក្រដាសវ៉ាស៊ិប្រពៃណីជប៉ុនទុកបោះត្រាលើទំព័រនីមួយៗ ហើយភ្ញៀវទេសចរមួយចំនួនកាន់សៀវភៅនេះជាប់តាមខ្លួន នៅពេលដែលពួកគេទៅគោរពនៅតាមទីសក្ការៈនានា ដើម្បីប្រមូលស្នាមត្រាបោះក្នុងសៀវភៅនេះ។ សៀវភៅបោះត្រា ហ្គុស៊ុអ៊ីន នៅទីនេះ មានក្របដែលរចនាតាមសំលៀកបំពាក់គីម៉ូណូ។ *រូបថត៖ Taniguchi Shoyudo Co.,Ltd*

### ខេត្តណារ៉ា៖ ស៊ូមិ ណុ អុប៊ឹជេ (សិល្បៈទឹកថ្នាំ ស៊ូមិ)

ខេត្តណារ៉ា ដែលធ្លាប់ជារាជធានីរបស់ជប៉ុនកាលពីសម័យបុរាណ គឺជាមជ្ឈមណ្ឌលផលិតទឹកថ្នាំ ស៊ូមិ (ទឹកថ្នាំខ្មៅសម្រាប់សរសេរអក្សរដោយប្រើជក់) តាំងពីយូរយារណាស់មកហើយ។ ទឹកថ្នាំ ស៊ូមិ ដ៏ប្រណិតត្រូវបានយកមកផលិតជារូបតាមរបាំងមុខដែលប្រើក្នុងល្ខោនរបាំមុខដែលពេញនិយមនៅសតវត្សទី៧ ដោយរក្សាវាទុកជាជាងយកមកប្រើប្រាស់។ *រូបថត៖ Kaori-zumi Asuka by KINKOEN*

ទំព័រទី១៨៖

## រសជាតិជប៉ុន៖ ពេលដែលគ្រូវទទួលទាន! ស្ករគ្រាប់ គុមិអាមិ

មានរាងតូច និងជាស្ករគ្រាប់រសជាតិផ្អែម ជាមួយនឹងតួអក្សរនានា

*រូបថត៖ គុរីហារ៉ា អុសាមុ*

*សហការ៖ ម៉ាយអាមិ (my ame)*

*រូបខាងលើ៖ ដុំស្ករគ្រាប់គុមិអាមិ ត្រូវបានទាញយ៉ាងវែង និងស្តើង(រូបខាងលើ) ហើយបន្ទាប់មកលុញឱ្យចេញជារាងស៊ីឡាំង(រូបកណ្ដាល) រួចពន្លាតវាក្លាយជាស្តើងទំហំមុខប្រហែល២សង់ទីម៉ែត្រ(រូបខាងក្រោម)*

*រូបថត៖ my ame*

*រូបខាងឆ្វេង៖ គុមិអាមិ ជាមួយនឹងតួអក្សរសេរសេរថា «អរគុណ» ជាភាសាជប៉ុន និងអង់គ្លេស*

គុមិអាមិ គឺជាស្ករគ្រាប់ដែលមានរូបរាងស៊ីឡាងដ៏វែង ដែលបង្ហាញនូវសណ្ឋានរូបដូចៗគ្នានៅពេលកាត់វាជាកង់ៗ។ វានឹងបង្ហាញនូវសណ្ឋានដូចៗគ្នាតាមការរចនា ដូចជាមុខរូបសត្វ រូបផ្កា និងរូបផ្លែឈើជាដើម។

តាំងពីយូរយារណាស់មកហើយ អាមិ ជាភាសាជប៉ុន មានន័យថាស្ករគ្រាប់ សំដៅទៅលើ មិហ្សឺអាមិ (ទឹកស្ករ) ដែលធ្វើឡើងដោយប្រើបាគឺហ្គា (មេដំបែ)លាយជាមួយម្សៅធញ្ញជាតិផ្សេងៗដូចជា អ៊ុរុឈិម៉ាអ៊ិ (អង្ករអ៊ុរុឈិជាប្រភេទអង្ករខ្សាយ) និងអាវ៉ា (ស្រូវមីយេ)ជាដើម ធ្វើវាឱ្យទៅជាស្ករ ហើយលុញច្របាច់ល្បាយទាំងនោះ ឱ្យរឹងក្លាយជាដុំស្ករគ្រាប់។ នៅពេលដែលស្ករទូទៅមានវត្តមានលក់យ៉ាងទូលំទូលាយនៅសម័យអេដុ (១៦០៣-១៨៦៨) គេបានយក មិហ្សឺអាមិ(ទឹកស្ករ) លាយបន្ថែមជាមួយស្ករទាំងនោះ ដែលធ្វើឱ្យវាមានរសជាតិកាន់តែផ្អែមខ្លាំង ហើយក្លាយជាស្ករគ្រាប់ដ៏ពេញនិយមក្នុងចំណោមសាធារណជនទូទៅ។

គុមិអាមិ លេចរូបរាងដំបូងនៅកំឡុងសម័យអេដុ។ ការរម្ងាស់លាយគ្នារវាង មិហ្សឺអាមិ និងស្ករ ក្លាយទៅជាម្សៅស្ករគ្រាប់ អាចបត់និងលុញទៅជារាងវែងៗបួន ឬប្រាំដុំ ហើយធ្វើវាឱ្យទៅជាដុំស្តើងៗ រួចបន្ថែមពណ៌។ ដុំស្តើងៗទាំងនោះ ត្រូវលុញបន្តទៅជារាងស៊ីឡាំងមានប្រវែងប្រហែល៣០សង់ទីម៉ែត្រ។ នៅពេលដុំស្តើងៗទាំងនោះត្រូវបានកាត់ រូបដែលរចនាមានសណ្ឋានដូចៗគ្នានឹងលេចរូបរាងឡើង។ ដំណាក់កាលទាំងនេះ គឺមានរយៈពេលត្រឹមតែ៣០ ទៅ៤០នាទីតែប៉ុណ្ណោះ នៅពេលដែលម្សៅស្ករគ្រាប់នៅក្តៅអ៊ុនៗ និងទន់នៅឡើយ ទើបអាចបង្កើតទៅជាដុំស្តើងៗបាន។ ការងារទាំងនេះ ត្រូវធ្វើដោយប្រញាប់ និងលុញជាប់រហូតដើម្បីរក្សារូបរាងស៊ីឡាំងឱ្យនៅល្អ មិនឱ្យខូចទ្រង់ទ្រាយនៃរូបរចនាពីដំបូង។

ស្ករគ្រាប់ទាំងនេះ មិនត្រឹមតែបង្ហាញនូវការរចនាជារូបភាពតែមួយមុខទេ តែមានការរចនាជាតួអក្សរផងដែរ។ គុមិអាមិ នៅខេត្តអៃឈិ ធ្វើការផលិតស្ករគ្រាប់រចនាទៅតាមការដាក់ស្នើ ឬ កុម្ម៉ង់របស់អតិថិជន។ ភាពលម្អិតចំពោះស្ករគ្រាប់នីមួយៗ ដែលអ្នកឯកទេសរចនាគុមិអាមិ បានផ្តល់នូវការណែនាំយ៉ាងលម្អិតលើពណ៌ និងវិធីសាស្រ្តក្នុងការតម្លើងសម្រាប់ដំណាក់កាលនីមួយៗ

បានបង្ហាញពីភាពស្មុគស្មាញនៅដំណាក់កាលតម្លើង ដោយទាមទារជុំម្សៅស្គរគ្រាប់ស្តើងៗប្រមាណ១០០មុខខុសៗគ្នា។ ការតម្លើងនីមួយៗ ទាមទារការយកចិត្តទុកដាក់ខ្លាំង ដោយសាររូបរាងនីមួយៗ ឬ ការតំរៀបមិនត្រង់ជួរនៃជុំស្តើងៗទាំងនោះ អាចនឹងធ្វើឱ្យអក្សរចេញមកអានមិនដាច់។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះគឺ ប្រសិនបើចំនួនតួអក្សរ ឬ អក្សរតូចពេក វានឹងពិបាកក្នុងការធ្វើឱ្យមានតុល្យភាពតួអក្សរ និងគម្លាតគែម ដែលធ្វើឱ្យពិបាកក្នុងការកែតម្រូវ។ ដូច្នេះវាត្រូវការបទពិសោធន៍ និងភាពពូកែស្ទាត់ជំនាញរបស់សិប្បករ ដើម្បីស្រមៃមើលឃើញជាមុននូវផលិតផលសម្រេច និងជំនាញក្នុងការតម្លើងជុំស្គរគ្រាប់ប្រកបដោយប្រសិទ្ធភាព។

ស្គរគ្រាប់ដែលមានតួអក្សរសរសេរបែបនេះ នឹងក្លាយជាមធ្យោបាយបង្ហាញពីអារម្មណ៍របស់ខ្លួន។ ស្គរគ្រាប់ទាំងនេះ គឺជាវត្ថុអនុស្សាវរីយ៍ដ៏សាមញ្ញដែលអាចបង្ហាញនូវសារលើកទឹកចិត្ត និងសារបង្ហាញនូវសណ្ដានចិត្តក្នុងរូបភាពដែលអាចមើលឃើញ។ វាអាចមានទំហំតូច ប៉ុន្តែប្រសិនបើដាក់តែមួយគ្រាប់នោះក្នុងមាត់របស់អ្នកនោះ ក្លិនដ៏ឆ្ងាញ់ពិសារ និងភាពផ្អែមល្ហែមនឹងសាយភាយបន្តិចម្តងៗដល់ជម្រៅនៃរាងកាយរបស់អ្នក។

<u>ទំព័រទី១៩៖</u>

<u>ទំព័រទី២០៖</u>

## ដើរកំសាន្តប្រទេសជប៉ុន៖ អិឈិហ្សេន

### ទីក្រុងដែលរក្សាវិធីសាស្ត្រផលិតក្រដាសវ៉ាស៊ិ ប្រពៃណីជប៉ុនឱ្យនៅតែបន្តគ្រប់ជំនាន់

អិឈិហ្សេន គឺជាតំបន់ផលិតក្រដាសវ៉ាស៊ិមួយចំនួននៅប្រទេសជប៉ុន។ តស៊ូទៅទស្សនាទេសភាពដែលបង្កប់នូវការងារសិប្បកម្មបន្តមករាប់ពាន់ឆ្នាំ។

*រូបថត៖ គុរីហារ៉ា អុសាមុ*



ទំព័រទី២១៖

*១. ក្រដាសវ៉ាស៊ិ អិឈិហៀន ដែលមានរូប ឬ ក្រឡានៅលើផ្ទៃក្រដាស*

*២. អគារប្រពៃណីជាច្រើនក្នុងស្រុកហ្គុកា។*

*៣. និង៤. ស្យ៉ាដេន (វិហារធំ) នៃព្រះវិហារ អុកាម៉ុតុ និង អូតាគិ ដែលត្រូវបានសង់ឡើងនៅសតវត្សរ៍ទី១៩។ វិហារនេះ គឺត្រូវបានសង់ឡើងដើម្បីគោរពបូជាដល់ កាវ៉ាកាមិ ហ្គុហៀន ទេពធីតាក្រដាស(រូបឆ្វេង)។*

*៥. ក្រដាសវ៉ាស៊ិ ធ្វើចេញពី កុហ្សុ (ម៉ុលប៊ើរី ឬ ដើមមនជប៉ុន)។ សរសៃទាំងនេះ គឺយកចេញពីមែកដើមមនជប៉ុនដែលបកសំបកហើយ។*

*៦. នៅសារមន្ទីរសិប្បកម្ម អ៊ុដាត្ស៊ឺ មានការបង្កើតក្រដាសដោយប្រើប្រាស់ឧបករណ៍ឈើបែបប្រពៃណី។*

*៧. ការសម្រិតសម្រាំងយកចេញនូវកម្ទេចធូលី និងសរសៃមិនល្អ បង្កើតបានជាក្រដាសវ៉ាស៊ិពណ៌សដ៏ស្រស់ស្អាត។*

ទំព័រទី២២៖

*៨. នៅ យ៉ាណាសិ ហ្សេហ្សូ សិអ៊ិស៊ីចុ អ្នកអាចទទួលបទពិសោធន៍បង្កើតក្រដាសដោយផ្ទាល់។*

*៩. ពុម្ពដែក ត្រូវបានដាក់លើក្រដាសវ៉ាស៊ិដែលទើបផលិតថ្មីៗ ហើយចាក់ទឹកចូលដើម្បីបង្កើតរូប ឬ ក្រឡាលើផ្ទៃក្រដាស។*

*១០. និង១១. ក្រដាសវ៉ាស៊ិដែលត្រូវបានជ្រលក់ពណ៌ និងចាក់ពុម្ព ក៏ត្រូវបានប្រើប្រាស់ដើម្បីបង្កើតជារបស់របរតូចៗ ដូចជា ឡៀបសៀវភៅដែលមានរាងដូចផ្តិតជាដើម (រូប១១)។*

*១២. និង១៣. ផលិតផលសិល្បៈទំនើបដាក់តាំងនៅក្នុងភូមិកាំបិតតាកិហ្វ៊ូ។ ឧបករណ៍សម្រាប់គាស់ស្រោមសំបុត្រ គឺជាវត្ថុអនុស្សាវរីយ៍ដ៏ពេញនិយម។*

ដោយធ្វើដំណើរប្រហែល៣ម៉ោងពីទីក្រុងតូក្យូ តាមរថភ្លើងល្បឿនលឿន ខ្សែហុគុរិគុ នឹងទៅដល់ស្ថានីយអិឈិហៀន តាកិហ្វ៊ូ ក្នុងទីក្រុងអិឈិហៀន ខេត្តហ្វ៊ុគុយ ដែលចាប់បើកឱ្យដំណើរការក្នុងរដូវផ្ការីកឆ្នាំ២០២៤។ ទីក្រុងនេះ ស្ថិតនៅក្នុងតំបន់ដែលព័ទ្ធជុំវិញដោយភ្នំជាច្រើនបីជ្រុង និងធ្លាប់ជាមជ្ឈមណ្ឌលនយោបាយរបស់ប្រទេស(កុគុហ្វ៊ុ) ដែលស្ថាប័នរដ្ឋបាលមូលដ្ឋានតាំងនៅ។ អិឈិហៀន ជាទីក្រុងដែលដើរតួជាច្រកចេញពីក្យូតុ ទៅកាន់តំបន់ហុគុរិគុ ដែលមមាញឹកនៃការផ្លាស់ទីទៅវិញទៅមកនៃប្រជាជន និងការផ្លាស់ប្តូរទំនិញ ដែលមានជាច្រើនរាប់សតវត្សរ៍ ហើយបានជំរុញឱ្យមានវប្បធម៌ពិសេសប្លែកតែមួយ និងឧស្សាហកម្មអូរិជីណាល ជាដើម។

ដាននៃប្រវត្តិតំបន់នេះ អ្នកអាចរកឃើញបាន នៅពេលដើរទស្សនាតាមព្រះវិហារ និងម៉ាឈិណាមិ(តំបន់ផ្ទះជាជួរតាមសងខាងផ្លូវ)។ ប៉ុន្តែប្រសិនបើអ្នកចង់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រ និងវប្បធម៌នៃតំបន់នោះ អ្នកគួរតែស្វែងយល់ពី «ក្រដាសវ៉ាស៊ិ អិឈិហ្សេន»។ ក្រដាសវ៉ាស៊ិ អិឈិហ្សេន ត្រូវបានគេកោតសរសើរចំពោះគុណភាពខ្ពស់របស់វានៅក្នុងឯកសារបុរាណចាប់ពីសតវត្សរ៍ទី៨។ នៅសម័យអេដូ (១៦០៣- ១៨៦៨) «អិឈិហ្សេនហូស្ស៊ោ» ត្រូវបានចាត់ទុកថាជាក្រដាសវ៉ាស៊ិ អិឈិហ្សេន ថ្នាក់ខ្ពស់បំផុត ដែលត្រូវបានប្រើប្រាស់សម្រាប់ឯកសារផ្លូវការរបស់ពួកអភិជន និងអ្នកដឹកនាំក្នុងជួរកងទ័ពស្យ៉ូហ្គុន។ ក្រោយមក ក្រដាសបែបនេះ ត្រូវបានប្រើប្រាស់ជាក្រដាសប្រាក់ និងជាក្រដាសសម្រាប់គំនូរជប៉ុន ហើយរហូតមកទល់សព្វថ្ងៃនេះ អិឈិហ្សេន គឺជាទីតាំងល្បីល្បាញសម្រាប់ការផលិតក្រដាសវ៉ាស៊ិដ៏ប្រណិតនៅប្រទេសជប៉ុន។

តំបន់ផលិតក្រដាសវ៉ាស៊ិ អិឈិហ្សេន គឺស្ថិតនៅស្រុកហ្គុកា ជាកន្លែងដែលមានព្រះវិហារអុកាម៉ុតុ និងអូតាគិ ដែលមាន កាវ៉ាកាមិហ្គុហ្សេន គឺជាទេពធីតាក្រដាស។

<u>ទំព័រទី២៣៖</u>

តាមផ្លូវនៃស្រុកហ្គុកា មានហាងសិប្បករផលិតក្រដាសវ៉ាស៊ិ ប្រមាណជា៥០ រហូតសព្វថ្ងៃនេះ។ ទីតាំងដំបូងនៃការទស្សនា គឺសារមន្ទីរសិប្បកម្ម អ៊ុដាត្ស៊ឹ។ សារមន្ទីរនេះកសាងឡើងនៅសតវត្សរ៍ទី១៨ ហើយបើកស្វាគមន៍សាធារណជន ដើម្បីទស្សនានូវរបៀបបង្កើតក្រដាសវ៉ាស៊ិដោយផ្ទាល់។ មែក ឬ ដើមមនជប៉ុន ដែលបកសំបកហើយ ត្រូវបានយកមកស្ងោរដើម្បីធ្វើឱ្យវាទន់ ហើយសម្រិតសម្រាំងយកកម្ទេចធូលីចេញ រួចដំវាឱ្យទៅជាសរសៃទន់ ប្រឡាក់ជាមួយសារធាតុម្យ៉ាងហៅថា ណិរី ដែលយកចេញពីរុក្ខជាតិ អែប៊ិកា ហើយដាក់ល្បាយនោះចូលទៅក្នុងធុងផលិតក្រដាសហៅថា ស៊ុគិប៊ឹណិ។ ឧបករណ៍ផលិតក្រដាសរាងស៊ុមឈើ ឬ ហៅថា ស៊ុហ្គិតា ត្រូវបានដាក់ល្បាយសារធាតុផលិតក្រដាសដែលរៀបរាប់ខាងលើចូល ហើយគ្រងវាដោយយោល ឬ រលាក់ទៅវិញមក ដោយថ្នមៗ ប៉ុន្តែរហ័ស ដើម្បីបានសន្លឹកបន្ទះក្រដាសដែលស្តើងពេញផ្ទៃនៃស៊ុហ្គិតា។ ក្រោយមក សន្លឹកបន្ទះក្រដាសត្រូវបានបកចេញពីស៊ូហ្គិតា ហើយដាក់ហាលឱ្យស្ងួតក្លាយជាសន្លឹកក្រដាសវ៉ាស៊ិយ៉ាងពេញលេញ។ ទិដ្ឋភាពសិប្បករផលិតក្រដាសដែលដាក់ដៃនៅក្នុងទឹកត្រជាក់ និងយោល ឬ រលាក់ ស៊ូហ្គិតា គឺជាទស្សនីយភាពមួយដែលត្រូវបានឃើញនៅតំបន់នេះ តាំងពីបុរាណកាលមក។

ដោយឡែក យ៉ាណាសិ រ្យោហ្សូ សិអ៊ិស៊ីចុ ប្រើប្រាស់វិធីសាស្ត្រផលិតក្រដាសវ៉ាស៊ិ អិឈិហ្សេន ដោយដៃបែបប្រពៃណីបែបនេះដែរ ក៏ប៉ុន្តែបញ្ចូលជាមួយនឹងបរិបថទំនើប។ ក្រដាសវ៉ាស៊ិដែលប្រើពុម្ពដែកដើម្បីបង្កើតរូប ឬ ក្រឡានៅលើផ្ទៃក្រដាស ត្រូវបានប្រើប្រាស់ធ្វើជាក្រដាសខ្ចប់វត្ថុនានា ឬ ជាក្របសៀវភៅជាដើម។ ជាក់ស្តែង អ្នកអាចទទួលបទពិសោធនៃសិក្ខាសាលាសាកល្បងបង្កើតក្រដាសវ៉ាស៊ិដោយផ្ទាល់បាន។

នៅក្បែរស្រុកហ្គុកា មានភូមិកាំបិតតាកិហ្វុ។ នៅភូមិនេះ អ្នកអាចឃើញជាងដែកយ៉ាងចំណាន កំពុងធ្វើការយ៉ាងស្វិតស្វាញ ដើម្បីបង្កើត អិឈិហ្សេន អ៊ុឈិហាម៉ុណុ(ផ្លែកាំបិត) ដែលបន្តមកជាង៧០០ឆ្នាំមកហើយ។ ឧបករណ៍គាស់សំបុត្ររចនាយ៉ាងវិចិត្រ និងកាំបិតប្រើប្រាស់ក្នុងចង្ក្រានបាយ ដែលត្រូវបានធ្វើឡើងយ៉ាងលម្អិតដោយសិប្បករមានឯកទេសប៉ិនប្រសប់នោះ ធ្វើឱ្យអ្នកលង់ស្រឡាញ់វត្ថុនោះភ្លាមតែម្តង។

នៅពេលដល់ម៉ោងទទួលទានអាហារហើយ អ្នកអាចឆ្ពោះទៅកាន់ទីក្រុងតំបន់ទីប្រជុំជន ដើម្បីភ្លក់រសជាតិអាហារប្រចាំតំបន់គឺមីសូបា អិឈិហ្សេន ដែលមានលក់នៅតាមភោជនីយដ្ឋានជាច្រើននៅទីនោះ។ សរសៃមី ដែលត្រូវបានរៀបចំពេញមួយចានជាមួយនឹងមើមផៃថាវក្រហមឈូសជាសរសៃៗ និងត្សឹកិស៊ិរឹ(ទឹកជ្រលក់) គឺជាអាហារប្រចាំតំបន់ ដោយសារភាពហាងនៃមើមផៃថាវក្រហម លាយជាមួយមីសូបាដែលមានក្លិនឈ្ងុយឆ្ងាញ់ បង្កើតជារសជាតិដ៏ជក់ចិត្ត។ «គូរ៉ាណុត្សឹជិ» ជាផ្លូវដែលពាណិជ្ជករប្រើប្រាស់ជញ្ជាំងពណ៌សនៃគូរ៉ា(អគារ ឬ ឃ្លាំងរក្សាទំនិញ)ឈរជាជួរទាំងនោះ ដោយជួសជុលកែច្នៃនូវគូរ៉ាចាស់ៗ ឱ្យមានបរិយាកាសទាក់ទាញ សម្រាប់អ្នកដំណើរអាចលំហែអារម្មណ៍ និងរីករាយទទួលទានកាហ្វេ ឬ បង្អែមបាននៅទីនោះ។

អិឈិហ្សេន គឺជាកន្លែងបណ្តុំនូវជំនាញ និងបច្ចេកទេសនានាជាច្រើនសតវត្សមកហើយ។ ការធ្វើដំណើរទៅកាន់តំបន់នេះនៃប្រទេសជប៉ុន គឺជាឱកាសមួយដ៏ពិសេសដើម្បីស្វែងយល់ពីសិប្បកម្មប្រពៃណីជប៉ុនក្នុងយុគសម័យទំនើបនេះ។

*១៤. និង១៥. មីសូបា អិឈិហ្សេន នៅអ៊ុស៊ីយ៉ា ជាភោជនីយដ្ឋានដែលបើកបម្រើអតិជនតាំងពីសតវត្សរ៍ទី១៩។*

*១៧. និង១៨. បង្អែម និងកាហ្វេជប៉ុន ជាឈុតកម្មង់ដ៏ពេញនិយមនៅហាងកាហ្វេហាយ៉ាស៊ី ដែលជាហាងកាហ្វេនៅលើផ្លូវគូរ៉ាណុត្សឹជិ។*

***ផែនទីតំបន់អិឈិហ្សេន***

*១ ព្រះវិហារ អុកាម៉ុតុ  និងអូតាគិ*

*២ សារមន្ទីរសិប្បកម្ម អ៊ុដាត្សឹ*

*៣ យ៉ាណាសិ ហ្សេហ្សូ សិអ៊ិស៊ីចុ*

*៤ ភូមិកាបិត តាកិហ្វូ*

*៥ អ៊ុស៊ីយ៉ា*

*៦ គូរ៉ាណុត្សឹជិ (ហាងកាហ្វេ ហាយ៉ាស៊ី)*

- ***មធ្យោបាយធ្វើដំណើរ***

  *ស្ថានីយរថភ្លើងអិឈិហ្សេន តាកិហ្វូ ចំណាយពេលប្រហែល៣ម៉ោងពីស្ថានីយរថភ្លើងតូក្យូ តាមខ្សែរថភ្លើនល្បឿនហុគុរិគុ។*

- ***ទំនាក់ទំនងព័ត៌មាន***

  *គេហទំព័រផ្លូវការសមាគមទេសចរ អិឈិហ្សេនស៊ិ*

  https://www.echizen-tourism-jp.e.any.hp.transer.com/

ទំព័រទី២៤៖

## វត្ថុអនុស្សាវរីយ៍របស់ជប៉ុន៖ ក្រដាសកត់ចំណាំប្លែកៗ

### ជាសម្ភារៈតុបតែងតុការិយាល័យ និងតុសាលារៀន

*រូបខាងលើ៖ ក្រដាសកត់ចំណាំ គុជាម៉ិម៉ុ មានរាងដូចជាផ្លែប៉ោម ឬផ្លែសារី (រូបថត៖ DRAFT Inc.)*
*រូបក្រោមខាងឆ្វេង៖ ហ្វ៊ូតាម៉ាតា ហ្វ៊ូសេន (ក្រដាសកត់ចំណាំដែលមានជើង) ដាក់បញ្ឈរ ដែលមានសារសរសេរថា «នេះគឺជាសម្ភារៈសម្រាប់ការប្រជុំថ្ងៃនេះ» (រូបថត៖ KING JIM CO., LTD.)*
*រូបក្រោមកណ្ដាល និងខាងស្ដាំ៖ សន្លឹកក្រដាសកត់ចំណាំ អ៊ុម៉ុស៊ីរ៉ុអ៊ិ ប្លក់ ប្រាសាទអូសាកា ដែលត្រូវបានហូតចេញម្ដងមួយៗ (រូបចំកណ្ដាល) ប្រាសាទនឹងលេចជារូបរាងម្ដងបន្តិចៗ(រូបខាងស្ដាំ) (រូបថត៖ TRIAD Inc.)*

ក្រដាសកត់ចំណាំ និងក្រដាសកត់ចំណាំស្អិត គឺងាយស្រួលទុកដាក់សម្រាប់ការសរសេរពាល់គំនិត និងសារនានាទៅកាន់នរណាម្នាក់។ ទោះបីជា ឧបករណ៍ឌីជីថល បានក្លាយជារបស់ប្រើប្រាស់ជំនួសជាទូទៅប្រចាំថ្ងៃ ក្រដាសកត់ចំណាំ ក៏មិនបានបាត់តួនាទី ឬ វត្តមានរបស់ខ្លួនក្នុងការិយាល័យ ឬ សាលារៀននៅជប៉ុនដែរ។

ក្រដាសទាំងនេះ មិនត្រឹមតែងាយប្រើប៉ុណ្ណោះទេ ថែមទាំងនាំយកនូវភាពសប្បាយរីករាយមកជាមួយផងដែរ។ ជាឧទាហរណ៍ អ្នកអាចបកសន្លឹកកត់ចំណាំចេញពីដុំក្រដាសកត់ចំណាំរាងផ្លែឈើ នោះប្រៀបដូចជាការកាត់ចំណិតផ្លែឈើដើម្បីទទួលទានអញ្ចឹង។ ឬក៏អ្នកអាចមើលទម្រង់ក្នុងលម្អដ៏ស្មុគស្មាញដែលនឹងលេចចេញពីដុំក្រដាសកត់ចំណាំនោះ នៅពេលដែលអ្នកហូតប្រើប្រាស់ក្រដាសនោះបន្តិចម្ដងៗ ទម្រង់រូបសិល្បៈមួយនឹងលេចរូបរាងបន្តិចម្ដងៗទៅតាមពេលវេលាដែលអ្នកប្រើប្រាស់វា។ ឬមួយក៏អ្នកអាចបង្កើតនូវកម្លាំងចិត្តដល់អ្នកទទួល ជាមួយនឹងក្រដាសកត់ចំណាំស្អិត ដោយផ្ដោតលើការរចនាតួអង្គស្អាតៗ ឬ បង្កើតសារនានា។

ក្រដាសកត់ចំណាំទាំងនេះ នឹងជួយលើកទឹកចិត្ត និងធ្វើឱ្យមានអារម្មណ៍ប្រសើរឡើង។ ក្រដាសកត់ចំណាំ និងក្រដាសកត់ចំណាំស្អិត ជាមួយនឹងការរចនាប្លែកៗ គឺបានដើរតួនាទីជួយយ៉ាងសំខាន់ដល់ការងារ និងការសិក្សា ដោយបន្ថែមភាពរីករាយផងដែរ។

*ទស្សនាវដ្ដី "និប៉ុនិកា" លេខ៣៦*
*បោះពុម្ពផ្សាយដោយក្រសួងការបរទេសជប៉ុន*
*២-២-១ កាស៊ឹមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*
*គេហទំព័រផ្លូវការរបស់ក្រសួង https://www.mofa.go.jp/*
*គេហទំព័រដែលផ្ដល់ព័ត៌មានអំពីជប៉ុន https://web-japan.org/*

**សម្រាប់សំណៅបកប្រែភាសាខ្មែរផ្សេងទៀត អាចចូលអានបាន តាមលីង ឬ QR Code ខាងក្រោមនេះ៖**
https://www.kh.emb-japan.go.jp/itpr_ja/11_000001_00654.html